ក្រសួងអប់រំ យុវជន និងកីឡា

Ministry of Education, Youth and Sport

វិទ្យាស្ថានជាតិអប់រំ

National Institute of Education

## និក្ខេបបទ

# បញ្ហាប្រឈមក្នុងការប្រើប្រាស់សៀវភៅសិក្សាគោលភាសាអង់គ្លេសនៅមធ្យមសិក្សាក្នុងខេត្តតាកែវ

# The Challenges of Using English Textbooks at High Schoolin Takeo Province

ដោយ / By

**ទុយ សុខា**

**TUY SOKHA**

ដើម្បីបំពេញលក្ខខណ្ឌបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៩

ឯកទេស៖ គ្រប់គ្រងអប់រំ

ឆ្នាំសិក្សា ២០២០-២០២២

ឧបត្ថម្ភដោយ៖ មូលនិធិគាំទ្រការអប់រំអន្តរជាតិនៅកម្ពុជា

Supported by Cambodia International Education Support Foundation ( CIESF )

ក្រសួងអប់រំ យុវជន និងកីឡា

Ministry of Education, Youth and Sport

វិទ្យាស្ថានជាតិអប់រំ

National Institute of Education

# និក្ខេបបទ

# បញ្ហាប្រឈមក្នុងការប្រើប្រាស់សៀវភៅសិក្សាគោលភាសាអង់គ្លេសនៅមធ្យមសិក្សាក្នុងខេត្តតាកែវ

# The Challenges of Using English TextbooksHigh School in Takeo Province

ដោយ / By

**ទុយ សុខា**

**TUY SOKHA**

ដើម្បីបំពេញលក្ខខណ្ឌបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៩

ឯកទេស៖ គ្រប់គ្រងអប់រំ

ឆ្នាំសិក្សា ២០២០-២០២២

គ្រូណែនាំគោល៖ បណ្ឌិត មឿន លិនណា

គ្រូណែនាំរង៖ លោក ម៉ៅ សារឿន

ឧបត្ថម្ភដោយ៖ មូលនិធិគាំទ្រការអប់រំអន្តរជាតិនៅកម្ពុជា

Supported by Cambodia International Education Support Foundation ( CIESF )

# សេចក្ដីប្រកាសអះអាងរបស់បេក្ខជន

ខ្ញុំបាទសូមបញ្ជាក់ថា និក្ខេបបទស្រាវជ្រាវដែលមានចំណងជើងថា "**បញ្ហាប្រឈមក្នុងការប្រើប្រាស់សៀវភៅសិក្សាគោលភាសាអង់គ្លេសនៅមធ្យមសិក្សាក្នុងខេត្តតាកែវ** សម្រាប់បំពេញលក្ខខណ្ឌសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំនៅវិទ្យាស្ថានជាតិអប់រំ គឺជាស្នាដៃរបស់ខ្ញុំបាទទាំងស្រុង ។ ស្នាដៃនេះពុំទាន់បានប្រើប្រាស់ ដើម្បីបំពេញលក្ខខណ្ឌសិក្សាសម្រាប់ទទួលសញ្ញាបត្រនៅវិទ្យាស្ថាននេះ សាកលវិទ្យាល័យណា ឬ វិទ្យាស្ថានថ្នាក់ស្មើណាមួយនៅឡើយទេ ។ ពុំមានសេចក្ដីដកស្រង់ ឬខ្លឹមសារអ្វីមួយត្រូវបានប្រើប្រាស់នៅក្នុងអត្ថបទស្រាវជ្រាវនេះដោយគ្មានការអនុញ្ញាតពីអ្នកនិពន្ធ ឬចុះបញ្ជីឯកសារយោងឡើយ។ និក្ខេបបទស្រាវជ្រាវខាងលើនេះ ពិតជាស្រាវជ្រាវដោយខ្ញុំបាទផ្ទាល់ពិតប្រាកដមែន ។

ថ្ងៃអាទិត្យ ១៣កើត ខែ កត្ដិក ឆ្នាំខាល ចត្វាស័ក ព.ស២៥៦៦

រាជធានីភ្នំពេញ, ថ្ងៃទី៦ខែ វិច្ឆិកា ឆ្នាំ២០២២

**ហត្ថលេខាបេក្ខជន**

**ទុយ សុខា**

# អារម្ភកថា

ដោយមើលឃើញថាភាសាអង់គ្លេស គឺជាភាសាមួយដែលត្រូវបានដាក់បញ្ចូលទៅក្នុងកម្មវិធីសិក្សា ដើម្បីឱ្យប្រជាជននៅក្នុងប្រទេសកម្ពុជាយើងបានទទួលការអប់រំខាងផ្នែកភាសា។ ព្រោះថាភាសាអង់គ្លេសត្រូវបានគេចាត់ទុកថាជាភាសាទីពីរសម្រាប់ទំនាក់ទំនងគ្នាបន្ទាប់ពីភាសាខ្មែរ។ យ៉ាងណាមិញក៏ជាភាសាបរទេស ដែលធ្វើឱ្យមានការលំបាកក្នុងការសិក្សាជាងភាសាជាតិយើងផងដែរ។

ជាការពិតណាស់ មិនថាតែការសិក្សាភាសាបរទេស ឬភាសាជាតិយើងនោះទេ សុទ្ធតែមានភាពងាយស្រួលខ្លះ ជួបការលំបាកខ្លះដោយមិនអាចគេចរួចឡើយ។ ដោយគ្រាន់តែមានជួបបញ្ហាតិចឬច្រើនតែប៉ុណ្ណឹង។

ដោយហេតុនេះហើយទើបបានខ្ញុំ សម្រេចថាលើកយកករណីមកធ្វើការសិក្សាស្រាវជ្រាវទៅលើប្រធានបទមួយស្តីពី“បញ្ហាប្រឈមក្នុងការប្រើប្រាស់សៀវភៅសិក្សាគោលភាសាអង់គ្លេសនៅមធ្យមសិក្សាក្នុងខេត្តតាកែវ” ក្នុងគោលបំណងចង់ស្វែងយល់ និងរកឱ្យឃើញពីកត្តាមួយចំនួនដែលជាបញ្ហាប្រឈមនៅក្នុងការអនុវត្តសៀវភៅសិក្សាគោលនៅមធ្យមសិក្សា។ ដោយខ្ញុំបាទជាអ្នកសិក្សាស្រាវជ្រាវទៅលើប្រធានបទនេះ ពុំបានចាត់ទុកថានេះគឺជាស្នាដៃដែលមានលក្ខណៈពេញលេញទាំងអស់នោះទេ ដោយគ្រាន់តែចង់បង្ហាញពីគោលគំនិតអំពីបញ្ហាប្រឈមក្នុងការប្រើប្រាស់សៀវភៅសិក្សាគោលភាសាអង់គ្លេសនៅមធ្យមសិក្សាតែប៉ុណ្ណោះ។ ទាំងអស់នេះគ្រាន់តែចង់ឆ្លុះបញ្ចាំង ពីការប្រឈមខ្លះៗទៅលើការសិក្សាភាសាអង់គ្លេសដើម្បីឱ្យអ្នកសិក្សាបានដឹងខ្លះៗផងដែរ។ហេតុដូច្នេះហើយ ខ្ញុំសូមការអភ័យទោសទុកជាមុននូវរាល់កំហុសឆ្គងដែលកើតមានដោយប្រការណាមួយ និងរងចាំទទួលនូវការរិះគន់ក្នុងន័យកែលម្អទៅលើស្នាដៃនេះ ពីមិត្តអ្នកអានគ្រប់ពេល ដោយក្តីរីករាយ។

# លិខិតបញ្ជាក់

បណ្ឌិត **មឿន លិនណា** ជាគ្រូណែនាំគោល

លោក **ម៉ៅ សារឿន** ជាគ្រូនាំរង

**សូមបញ្ជាក់ និងទទួលស្គាល់ថា**

**លោក ទុយ សុខា** ជានិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៩ ពិតជាបានសរសេរនិក្ខេបបទស្រាវជ្រាវ "**បញ្ហាប្រឈមក្នុងការប្រើប្រាស់សៀវភៅសិក្សាគោលភាសាអង់គ្លេសនៅមធ្យមសិក្សាក្នុងខេត្តតាកែវ**" ពិតប្រាកដមែន។

ថ្ងៃអាទិត្យ ១៣កើត ខែកក្ដិក ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី ៦ ខែវិច្ឆិកា ឆ្នាំ២០២២





..................................... ...................................

**បណ្ឌិត មឿន លិនណា** **លោក ម៉ៅ សារឿន**

# សេចក្តីថ្លែងអំណរគុណ

ជាកិច្ចដំបូងខ្ញុំបាទជានិស្សិតឈ្មោះទុយសុខាសូមថ្លែងអំណរគុណយ៉ាងធំធេងចំពោះក្រសួងអប់រំ យុវជន និងកីឡា និងវិទ្យាស្ថានជាតិអប់រំ ព្រមទាំងអង្គការមូលនិធិគាំទ្រការអប់រំអន្តរជាតិកម្ពុជា ( Cambodia International Education Support Foundation ( CIESF ) ដែលបានរៀបចំឱ្យមានកម្មវិធីអាហារូបករណ៍នេះឡើង ដែលជាឱកាសល្អមួយសម្រាប់ខ្ញុំបាទបានមកចូលរួមសិក្សានៅក្នុងថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ និងផែនការអប់រំនេះ ក្នុងការពង្រីកនិងពង្រឹងទៅលើចំណេះដឹងបន្ថែម ដើម្បីយកទៅប្រើប្រាស់ និងបានចូលរួមចំណែកក្នុងការអភិវឌ្ឍប្រទេសជាតិក្នុងវិស័យអប់រំ។

ខ្ញុំបាទសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះឯកឧត្តម លោក លោកស្រី ជាសាស្ត្រាចារ្យទាំងអស់ ដែលបានលះបង់ពេលវេលាដ៏មានតម្លៃរបស់លោកក្នុងការចែករំលែកនូវចំណេះដឹង និងបទពិសោធដែលមិនអាចកាត់ថ្លៃបាន ដល់ខ្ញុំបាទ ព្រមទាំងយើងខ្ញុំទាំងអស់គ្នា។ ខ្ញុំបាទសូមថ្លែងអំណរគុណជាពិសេសចំពោះ បណ្ឌិត **មឿន លិនណា** ដែលជាគ្រូណែនាំ និងលោក **ម៉ៅ សារឿន** ដែលជាគ្រូណែនាំរង ដោយលោកទាំងពីរបានលះបង់ពេលវេលាដ៏មានតម្លៃក្នុងការជួយណែនាំបង្ហាញផ្លូវឆ្ពោះទៅដល់គោលដៅ។សូមអរគុណដល់មិត្តភ័ក្តិទាំងអស់ដែលតែងតែជួពន្យល់ណែនាំ និងចែករំលែកនូវបទពិសោធល្អៗ ទាំងពេលកំពុងសិក្សា និងពេលកំពុងស្រាវជ្រាវ ។

សូមថ្លែងអំណរគុណដ៏ជ្រាលជ្រៅដល់អ្នកម្តាយ និងលោកឪពុកដ៏មានគុណ បង និងប្អូន ដែលលោកតែងតែស្ថិតនៅក្នុងចិត្តចាំជួយជំរុញលើកទឹកចិត្តគ្រប់ពេលវេលា ។

ខ្ញុំសូមជូនប្រសិទ្ធិពរដ៏បវរមហាប្រសើរ ជូនចំពោះ ឯកឧត្តម លោក លោកស្រី នាងកញ្ញា ទទួលបាននូវសុខភាពល្អបរិបូរណ៍ សុភមង្គល និងជោគជ័យគ្រប់ភារកិច្ច ព្រមទាំងទទួល បាននូវពុទ្ធពរទាំងបួនប្រការ គឺអាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

**សូមអរគុណ!**

# មូលន័យសង្ខេប

ការសិក្សាលើប្រធានបទស្តីពី *"បញ្ហាប្រឈមក្នុងការប្រើប្រាស់សៀវភៅសិក្សាគោលភាសាអង់គ្លេសនៅមធ្យមសិក្សាក្នុងខេត្តតាកែវ"* នាពេលនេះ ធ្វើឡើងស្របពេលជាមួយនឹងកំណែទម្រង់វិស័យអប់រំរបស់ក្រសួងអប់រំ យុវជន និងកីឡា ដែលបានដាក់អោយប្រើប្រាស់ទៅលើសៀវភៅសិក្សាគោលភាសាអង់គ្លេសដែលទើបនិងកែប្រែថ្មី។ ការសិក្សាស្រាវជ្រាវនេះមានគោលបំណង ១- ស្វែងយល់ពីការយល់ទៅលើការអនុវត្ត និងបញ្ហាប្រឈមក្នុងការប្រើប្រាស់សៀវភៅភាសាអង់គ្លេសថ្មីនៅមធ្យមសិក្សាទុតិយភូមិ ២- ស្វែងយល់ពីទស្សនៈយល់ឃើញជារួមរបស់គ្រូទៅលើការអនុវត្តក្នុងការប្រើប្រាស់សៀវភៅសិក្សាគោល។ ការស្រាវជ្រាវនេះត្រូវបានធ្វើឡើងតាមបែបគុណវិស័យ។ ភាគសំណាកក្នុងការស្រាវជ្រាវគឺគ្រូបង្រៀន គ្រូបង្គោល និង ដោយប្រើកម្រងសំណួរសម្ភាសន៍ជាឧបករណ៍ស្រាវជ្រាវឲ្យសំណាកបំពេញ។ ជាលទ្ធផល គ្រូភាគច្រើនបាន យល់ដឹងច្បាស់ និងអនុវត្តបានល្អលើការរៀបចំផែនការមេរៀន (Plan)។ ការរអនុវត្តការបង្រៀន និងការសង្កេត (Do) ការពិភាក្សាការបង្រៀន និងរៀន (Check) និងការធ្វើសកម្មភាពកែលម្អបន្ត (Action) នៃដំណើរការសិក្សាមេរៀន។ ទាំងនេះបានឆ្លុះបញ្ចាំងឲ្យឃើញពីការយកចិត្តទុកដាក់ខ្ពស់ក្នុងការលើកកម្ពស់គុណភាពបង្រៀនរបស់ពួកគាត់។ តែទោះបីជាយ៉ាងណាក៏ដោយក៏នៅមានបញ្ហាប្រឈមខ្លះកើតឡើង ដែលមានជាអាទិ៍ បញ្ហាប្រឈមទៅលើសៀវភៅសិក្សាគោល សម្ភារឧបទេស វិធីសាស្ត្របង្រៀន គ្រូបង្រៀន សិស្ស សាលារៀន សហគមន៍ និងកត្តាផ្សេងៗទៀត ប៉ុន្តែគ្រូមួយចំនួនតូចក៏បានចូលរួមសិក្សាមេរៀនមិនបានទៀងទាត់ ការគាំទ្រថវិកា និងសម្ភារលើការអនុវត្តសៀវភៅសិក្សាគោល និងមេរៀននៅមានកំណត់នៅឡើយ។ តែទោះបីជាយ៉ាងនេះក្តី លោកគ្រូអ្នកគ្រូនៅមានទស្សនៈយល់ឃើញជារួមថា ការអនុវត្តទៅលើសៀវភៅសិក្សាគោល ឬការសិក្សាមេរៀនគឺពិតជានៅមានបញ្ហាប្រឈមមួយចំនួនដែលបានធ្វើឱ្យមានការរាំងស្ទះក្នុងការអនុវត្តទៅលើសៀវភៅសិក្សាគោលភាសាអង់គ្លេសនៅមធ្យមសិក្សាពិតមែន តែក៏បានជួយអភិវឌ្ឍសមត្ថភាពវិជ្ជាជីវៈគ្រូបង្រៀនរបស់ពួកគាត់ បានជួយបង្កើនទំនាក់ទំនង និងសាមគ្គីភាពផ្ទៃក្នុងល្អ ហើយលទ្ធផលសិក្សារបស់សិស្សបានល្អជាងមុន។ ជាសេចក្តីសន្និដ្ឋាន ពិតជាចំណែកមួយល្អក្នុងការចូលរួមអភិវឌ្ឍការបង្រៀនរបស់លោកគ្រូ អ្នកគ្រូ និងការរៀនសូត្ររបស់សិស្ស។ កម្មវិធីនេះពិតជាបានរួមចំណែកដល់ការអនុវត្តគោលនយោបាយអប់រំ និងកំណែទម្រង់វិស័យអប់រំនៅកម្ពុជា។

// Abstruct

Study on the topic “Challenges in the use of language textbooks English in Takeo province – now in line with the Ministry of Education, Youth and Sports’ education reforms Newly revised English textbook This research aims to: 1- Understand the understanding of the implementation and challenges of using the textbook * New English in high school 2. Understand the overall perspective of Teachers on the practice of using the textbook. This research was conducted qualitatively. The research sample was teachers and trainers and using the questionnaire as a research tool to complete the sample. As a result, most teachers have a clear understanding and good practice of lesson planning, implementation, teaching and observation (Do), discussion, teaching and learning (Check) and activities to improve (Action). Lesson learning process. These reflect a strong focus on improving the quality of their teaching. However, there are still some challenges, such as the challenge of textbooks, teaching materials, teaching methods, teachers, students, schools, communities and other factors, but a small number of teachers did not participate in the lessons. Regular budget and material support for the implementation of textbooks, lessons and lessons is still limited. However, teachers are still of the general view that the implementation of the textbook or the lesson is that there are still some challenges that have hindered the implementation of the textbook. Basic English in high school, but also helped to develop the professionalism of their teachers, helped to increase good internal communication and solidarity, and the academic results of the students Teach Better Before. Is His Teacher You Teacher and Implementation of education policies and Conclusion Learn Version Of True In part One Good in This Participation Is Development True Contributed The To Applications Students. Sector profile Education In Cambodia.

# មាតិកា

សេចក្តីប្រកាសអះអាងរបស់បេក្ខជន....................i
អារម្ភកថា....................ii
លិខិតបញ្ជាក់....................iii
សេចក្តីថ្លែងអំណរគុណ....................iv
មូលន័យសង្ខេប....................v
ជំពូកទី១៖សេចក្តីផ្តើម....................1
១.១- លំនាំបញ្ហា....................1
១.២- បញ្ហានៃការស្រាវជ្រាវ....................3
១.៣- គោលបំណងនៃការស្រាវជ្រាវ....................4
១.៣.១- គោលបំណង....................4
១.៣.២- សំណួរស្រាវជ្រាវ....................4
១.៣.៣- សារៈសំខាន់នៃការស្រាវជ្រាវ....................5
១.៤- ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ....................5
១.៤.១- ដែនកំណត់នៃការស្រាវជ្រាវ....................5
១.៤.២- វិសាលភាពនៃការស្រាវជ្រាវ....................6
១.៥- រចនាសម្ព័ន្ធស្រាវជ្រាវ....................6
ជំពូក២៖រំលឹកទ្រឹស្តី....................9
២.១- និយមន័យនៃពាក្យគន្លឹះ....................9
២.១.១- បញ្ហាប្រឈម....................9
២.១.២- សៀវភៅសិក្សាគោល....................9
២.១.៣- ភាសាអង់គ្លេស....................9
២.២- សាវតាការអនុវត្តសៀវភៅសិក្សាគោលភាសាអង់គ្លេស....................10

២.៣- ទស្សនៈផ្សេងៗនៃបញ្ហាប្រឈមក្នុងការប្រើប្រាស់សៀវភៅសិក្សាគោលភាសាអង់គ្លេស……………………………………………………..12
ជំពូក៣៖ វិធីសាស្ត្រស្រាវជ្រាវ……………………………………………………..16
៣.១- វិធីសាស្ត្រស្រាវជ្រាវ..........................................................................................16
៣.២- ការជ្រើសរើសភាគសំណាក ...................................................................................16
៣.៣- ឧបករណ៍ស្រាវជ្រាវ...............................................................................................17
៣.៤- ការប្រមូលទិន្នន័យ ...............................................................................................18
៣.៥- ការវិភាគទិន្នន័យ .................................................................................................19
ជំពូក៤៖ទិដ្ឋភាពនានានៃវិទ្យាល័យក្នុងខេត្តតាកែវ .......................................................22
៤.១- សាវតាខេត្តតាកែវ ...............................................................................................22
៤.២-វិស័យអប់រំ ........................................................................................................ 22
៤.៣- ស្ថិតិបុគ្គលិក និងចំនួនសិស្ស .................................................................................. 23
៤.៤- ទិដ្ឋភាពពីវិទ្យាល័យត្នោតមាស ..................................................................................23
៤.៤.១- ព័ត៌មានអំពីសាលា.............................................................................................23
៤.៤.២-ប្លង់វិទ្យាល័យត្នោតមាស ......................................................................................24
៤.៤.៣- រូបភាពនានានៃវិទ្យាល័យ ...................................................................................25
៤.៥-ទិដ្ឋភាពនៃវិទ្យាល័យ ម៉ុន រ៉ានី ហ៊ុនសែន បាទី ........................................................26
៤.៥.១- ប្រវត្តិសង្ខេបវិទ្យាល័យ ម៉ុន រ៉ានី ហ៊ុនសែន បាទី ....................................................26
៤.៥.២-ព័ត៌មានពីសាលា .................................................................................................28
៤.៥.៣- ប្លង់វិទ្យាល័យ ម៉ុន រ៉ានី ហ៊ុនសែន បាទី ...............................................................28
៤.៦- ទិដ្ឋភាពនៃវិទ្យល័យសម្ដេចឪ ...............................................................................29
៤.៦.១- ព័ត៌មានអំពីសាលា.............................................................................................29
៤.៦.២- ខាងក្រោមនេះជាប្លង់វិទ្យាល័យសម្ដេចឪ ................................................................30
៤.៦.៣- រូបភាពខ្លះៗនៃវិទ្យាលឋ័យ……………………………………………..31

៤.៧- ទិដ្ឋភាពនៃវិទ្យាល័យហេងសំរិនព្រៃល្វា ...................................................32
៤.៧.១- ព័ត៌មានអំពីសាលា ...................................................................................32
៤.៧.២- រូបភាពខ្លះនៃវិទ្យាល័យហេងសំរិនព្រៃល្វា ..............................................33
ជំពូក៥ៈលទ្ធផល និងការពិភាក្សា.........................................................................35
៥.១- ការសិក្សាពីបញ្ហាប្រឈមនៅក្នុងសៀវភៅគោលចាស់ .......................................35
៥.១.១-បញ្ហាប្រឈមនៃមេរៀន.....................................................................................35
៥.១.២- បញ្ហាប្រឈមនៃខ្លឹមសារមេរៀន.......................................................................35
៥.១.៣- បញ្ហាប្រឈមលើវិធីសាស្ត្រនៃការរៀបចំមេរៀន ................................................36
៥.១.៤- បញ្ហាប្រឈមទាក់ទងនិងសម្ភារឧបទេស...........................................................37
៥.១.៥- បញ្ហាប្រឈមនៃវិធីសាស្ត្របង្រៀន .....................................................................37
៥.១.៦- សេចក្តីសន្និដ្ឋាន.............................................................................................38
៥.២. ការសិក្សាពីបញ្ហាប្រឈមនៅក្នុងសៀវភៅសិក្សាថ្មី.................................................38
៥.២.១- បញ្ហាប្រឈមនៃមេរៀន.....................................................................................39
៥.២.២- បញ្ហាប្រឈមនៃខ្លឹមសារមេរៀន.......................................................................39
៥.២.៣- បញ្ហាប្រឈមនៃវិធីសាស្ត្ររៀបចំមេរៀន ...........................................................40
៥.២.៤- បញ្ហាប្រឈមទាក់ទងនិងសម្ភារបង្រៀន.............................................................40
៥.២.៥- បញ្ហាប្រឈមនៃវិធីសាស្ត្របង្រៀន.......................................................................41
៥.៣- បញ្ហាប្រឈមផ្សេងៗ ...........................................................................................42
៥.៣.១- ការទាក់ទងសៀវភៅសិក្សាគោល ......................................................................42
៥.៣.២- សមត្ថភាពគ្រូ....................................................................................................42
៥.៤- ការប្រៀបធៀបបញ្ហាប្រឈមរវាងសៀវភៅចាស់ និងសៀវភៅថ្មី និង
កត្តាផ្សេងៗ ...........................................................................................................43
៥.៤.១- បញ្ហាប្រឈមមានលក្ខណៈដូចគ្នារវាងសៀវភៅចាស់ សៀវភៅថ្មី
និងកត្តាផ្សេងៗ ......................................................................................................43

៥.៤.២- បញ្ហាប្រឈមមានលក្ខណៈខុសគ្នានៅក្នុងសៀវភៅចាស់និងសៀវភៅថ្មីនិងកត្តេផ្សេងៗ……………………….………………………………………………..44
៥.៥- សេចក្តីសន្និដ្ឋាន....................................................................................44
ជំពូក៦៖សេចក្តីសន្និដ្ឋាន អនុសាសន៍ និងសំណូមពរ......................................47
៦.១- សេចក្តីសន្និដ្ឋាន.................................................................................... 47
៦.២- ការផ្តល់អនុសាសន៍ ..............................................................................48
៦.៣- សំណូមពរ ........................................................................................... 48
-ឯកសារយោង………………………………………………………………………..49
-ឧបសម្ព័ន្ធ ................................................................................................53

# ជំពូក១
# សេចក្តីផ្តើម

# ជំពូក១
# សេចក្តីផ្តើម

## ១.១- លំនាំបញ្ហា

ការអប់រំ គឺជាកត្តាមួយដែលចាំបាច់ក្នុងការបង្កើតធនធានមនុស្សឱ្យមានសមត្ថភាព គុណភាព និងជំនាញក្នុងការកសាងប្រទេសឱ្យមានភាពរីកចម្រើន ទាំងបច្ចេកវិទ្យា ទាំងភាសា ដើម្បីឱ្យក្លាយទៅជាធនធានដែលមានសមត្ថភាព គុណភាព ដើម្បីឆ្ពោះទៅរកការរីកចម្រើន និងការអភិវឌ្ឍសង្គម។

ដោយភាពចាំបាច់របស់សង្គមក្នុងការអភិវឌ្ឍទៅលើគ្រប់វិស័យ ពិសេសវិស័យអប់រំ។ ការអប់រំត្រូវបានយកចិត្តទុកដាក់ជាខ្លាំង ក្នុងការបណ្តុះបណ្តាលធនធានមនុស្សឱ្យមានសមត្ថភាពប្រកបដោយគុណភាព សុជីវធម៌ ជំនាញ បច្ចេកវិទ្យា និងភាសា ដើម្បីឆ្លើយតបទៅនិងសង្គមសម័យឌីជីថល។

មិនតែប៉ុណ្ណោះនៅក្នុងវិស័យអប់រំ ក៏មានការកែប្រែទៅលើកម្មវិធីសិក្សាផងដែរទាំងកម្មវិធីសិក្សាខ្មែរ និងកម្មវិធីសិក្សាលម្អិតភាសាអង់គ្លេស។ ដោយភាសាមានភាពចាំបាច់ក្នុងការទំនាក់ទំនងឬប្រាស្រ័យទាក់ទងរវាងជាតិសាសន៍មួយទៅជាតិសាសន៍មួយទៀតក្នុងការរស់នៅប្រចាំថ្ងៃឬការងារដែលមនុស្សគ្រប់គ្នាបានប្រើ។

ក្នុងវិស័យអប់រំនៅក្នុងប្រទេសកម្ពុជា មុខវិជ្ជាភាសាអង់គ្លេស ក៏ជាមុខវិជ្ជាមួយដែលបានចូលរួមក្នុងការបណ្តុះបណ្តាលទៅដល់សិស្សានុសិស្ស និងអ្នកសិក្សាដ៏ទៃទៀត ដើម្បីទទួលបាននៅចំណេះដឹង មានទំនាក់ទំនងជាមួយពិភពលោក ដែលជាធនធានប្រកបដោយសមត្ថភាព គុណភាព ជំនាញ បច្ចេកវិទ្យា វិទ្យាសាស្ត្រ ព្រមទាំងភាសាផងដែរក្នុងការអភិវឌ្ឍសង្គមអោយមានភាពរីកចម្រើនទាន់សម័យទំនើប។

ទន្ទឹមនឹងមានការកំណែទម្រង់លើវិស័យអប់រំនៅក្នុងប្រទេសកម្ពុជា បច្ចុប្បន្នរាជរដ្ឋាភិបាលកម្ពុជាបានខិតខំប្រឹងប្រែង និងមានចក្ខុវិស័យ ប្រែក្លាយប្រទេសកម្ពុជាទៅជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ ។ ហើយម្យ៉ាងទៀតដើម្បីសម្រេចបាននូវចក្ខុវិស័យនេះ ការកសាងធនធានមនុស្សឲ្យមានសមត្ថភាពខ្ពស់គឺជាគន្លឹះមួយយ៉ាងសំខាន់បំផុត សម្រាប់ឆ្លើយតបទៅនឹងបរិបទសកលភាវូបនីយកម្ម សមាហរណកម្មក្នុងតំបន់ និងធានាបានការប្រកួតប្រជែងក្នុងទីផ្សារពលកម្មដោយបើកចំហរ។ នេះហើយដែលតម្រូវឲ្យក្រសួងអប់រំ យុវជន និងកីឡាខិតខំបំពេញតួនាទីចម្បងក្នុងការកសាងនិងអភិវឌ្ឍន៍ធនធានមនុស្សប្រកបដោយគុណភាព និងគុណធម៌ ដែលជាធាតុយ៉ាងសំខាន់លើគ្រប់វិស័យដើម្បីកសាងសង្គមកម្ពុជាឲ្យក្លាយទៅជាសង្គមមួយរីកចម្រើនដោយផ្អែក

ទៅលើចំណេះដឹង និងចំណេះធ្វើជាមូលដ្ឋាន (ក្រសួង អយក,២០១៦)។ម្យ៉ាងវិញទៀត ដោយសារប្រទេសជាតិមានការអភិវឌ្ឍរីកចម្រើនឥតឈប់ឈរ ទើបធ្វើឲ្យវិស័យអប់រំបានដើរតួនាទីយ៉ាងសំខាន់ និងត្រូវបានយកចិត្តទុកដាក់កែលម្អជាច្រើនផ្នែក ដូចជាកម្មវិធីសិក្សា សៀវភៅសិក្សាគោល ក៏ដូចជាវិធីសាស្ត្រនៃការបង្រៀន ជាពិសេស បរិមាណ និងគុណភាពឱ្យបានល្អប្រសើរ។

គុណភាពអប់រំជាកត្តាដ៏សំខាន់មួយក្នុងការអភិវឌ្ឍធនធានមនុស្ស ដែលទាមទារឱ្យក្រសួងអប់រំយុវជន និងកីឡាត្រូវមានការត្រួតពិនិត្យតាមដាន និងវាយតម្លៃជាប្រចាំ ដោយផ្អែកលើច្បាប់ គោលនយោបាយ សេចក្តីណែនាំ និងគោលការណ៍នានាដើម្បីឲ្យសម្រេចតាមយុទ្ធសាស្ត្រវិស័យអប់រំ និងវិធានការកំណែទម្រង់វិស័យអប់រំ (ក្រសួង អយក,២០១៥)។ បន្ថែមលើនេះ ការអនុវត្តទៅលើកម្មវិធីសិក្សា និងសៀវភៅសិក្សាគោលក៏មានសារសំខាន់ណាស់ ក្នុងការពង្រឹងគុណភាពអប់រំ ជាពិសេសបានជំរុញបុគ្គល និងអង្គភាពនីមួយៗបំពេញការងារប្រកបដោយប្រសិទ្ធភាព និងមានទំនួលខុសត្រូវខ្ពស់ (ក្រសួង អយក, ២០០៨)។

លើសពីនេះទៅទៀត ខ្លឹមសារសិក្សាត្រូវឆ្លុះបញ្ចាំងនូវភាពទាក់ទងគ្នារវាងកម្មវិធីសិក្សា សៀវភៅសិក្សាគោល សម្ភារសិក្សា និងជំនាញមូលដ្ឋានរបស់ពួកគេ។ ក្នុងដំណើរការបង្រៀន គ្រូត្រូវប្រើវិធីសាស្ត្របង្រៀនតាមបែបគោលវិធីសិស្សមជ្ឈមណ្ឌល ដោយមានការគ្រប់គ្រងថ្នាក់រៀនយ៉ាងល្អ និងការវាយតម្លៃសាលារៀនប្រកប ដោយជំនាញ ដើម្បីសម្រួលដល់ការបង្រៀន និងរៀន និងកាត់បន្ថយនៅភាពមិនស៊ីគ្នា។ លទ្ធផលសម្រេចបានដែលរួមមានចំណេះដឹង បំណិន និងឥរិយាបទនឹងត្រូវផ្សាភ្ជាប់ទៅនឹងគោលដៅអប់រំជាតិ និងការចូលរួមជាវិជ្ជាមានក្នុងសង្គម (UNICEF, 2000)។ ជាមួយគ្នានេះ គុណភាពអប់រំបានមកពីលក្ខណៈច្រើនយ៉ាង ដូចជាគុណភាពសិស្ស គុណភាពគ្រូ បរិស្ថានសិក្សា ការផ្តល់សេវាកម្ម គុណភាពខ្លឹមសារនៃកម្មវិធីសិក្សារួមជាមួយនឹងសៀវភៅសិក្សាគោលផង គុណភាពនៃដំណើរការបង្រៀន លក្ខខណ្ឌធ្វើការងាររបស់គ្រូបង្រៀន និងគុណភាពលទ្ធផលសិក្សា (S.G.N Eze, 2017)។

ជាការពិតណាស់ បើនិយាយពីគុណភាពអប់រំ ក៏ត្រូវនិយាយផងដែរពីគុណភាពគ្រូបង្រៀន សៀវភៅសិក្សាគោល ដូចបានលើកឡើងនៅក្នុងកំណែទម្រង់វិស័យអប់រំ។ គ្រូបង្រៀនដែលមានសមត្ថភាពខ្ពស់ជាគន្លឹះក្នុងការជួយសិស្សឲ្យសម្រេចបានលទ្ធផលល្អប្រសើរក្នុងការសិក្សា។ បច្ចុប្បន្ននេះ ក្រសួងអប់រំ យុវជន និងកីឡាកំពុងយកចិត្តទុកដាក់រៀបចំឯកសារគតិយុត្ត ការជ្រើសរើស ការបណ្តុះបណ្តាល ការគាំទ្រគ្រប់ផ្នែក និងបង្កើតយន្តការទាក់ទាញអ្នកដែលមានសមត្ថភាពខ្ពស់ឲ្យចូលបម្រើការក្នុងវិជ្ជាជីវៈគ្រូបង្រៀន។ ការបណ្តុះ បណ្តាលគ្រូបង្រៀនដ៏មានប្រសិទ្ធភាពគឺជា

គន្លឹះនៃកំណែទម្រង់ប្រព័ន្ធបណ្តុះបណ្តាលគ្រូបង្រៀន(ក្រសួង អយក, ២០១៥)។ គុណភាពគ្រូបង្រៀនមានទំនាក់ទំនងយ៉ាងខ្លាំងនឹងលទ្ធផលសិក្សារបស់សិស្សដោយផ្អែកលើកម្មវិធីសិក្សាដែរ។

ដោយឃើញពីសារៈនៃមុខវិជ្ជាភាសាអង់គ្លេស ដូចដែលបានរៀបរាប់ខាងលើ ក្រសួងអប់រំបានព្យាយាមយកចិត្តទុកដាក់ជាខ្លាំងដើម្បីបង្កើតនៅធនធានមនុស្សដែលមានសមត្ថភាព ដោយធ្វើការកែលម្អនៅកម្មវិធីសិក្សាភាសាអង់គ្លេសឱ្យមានការអនុវត្តនៅតាមគ្រឹះស្ថានសិក្សាសាធារណៈដើម្បីឆ្លើយតបទៅនិងបរិបទថ្មី ក្នុងការបណ្តុះបណ្តាលធនធានមនុស្សអោយឆ្លើយតបទៅនិងសង្គមប្រកបដោយធនធានដែលមានសមត្ថភាព គុណភាព សុជីវធម៌ សីលធម៌ ជំនាញ និងបច្ចេកវិទ្យា។

ក្រសួងអប់រំ យុវជន និងកីឡាសង្ឃឹមថា គ្រប់គ្រឹះស្ថានសិក្សា គ្រប់ស្ថាប័នអប់រំ និងស្ថាប័នដែលមានការពាក់ព័ន្ធ និងមានការចូលរួមគាំទ្រជាមួយក្រសួងអប់រំ យុវជន និងកីឡា ក្នុងការអនុវត្តទៅលើកម្មវិធីសិក្សាលម្អិតភាសាអង់គ្លេសនេះឱ្យមានប្រសិទ្ធភាពនៅគ្រប់កម្រិតសិក្សា ដើម្បីជួយក្នុងការបណ្តុះបណ្តាលធនធានមនុស្សឱ្យមានសមត្ថភាព និងជំនាញពិត។

ក្រសួងអប់រំ យុវជន និងកីឡា ពិតជាសូមថ្លែងអំណរអរគុណជាអនេក ចំពោះគណៈកម្មការអភិវឌ្ឍន៍កម្មវិធីសិក្សា គ្រប់ស្ថាប័នអប់រំ លោកគ្រូ អ្នកគ្រូ ដែលបានប្រឹងប្រែង អស់ពីកម្លាំងកាយចិត្តក្នុងការសម្រេចបាននូវលទ្ធផលដល់សង្គមជាតិយើង។

បន្ទាប់ពីសង្កេតឃើញពីសារៈប្រយោជន៍នៃភាសាអង់គ្លេសក្នុងការជួយអភិវឌ្ឍធនធានមនុស្សឱ្យក្លាយជាធនធានដ៏ជោគជ័យនាថ្ងៃអនាគតដូច្នឹងហើយ ទើបស្នេរសម្រេចចិត្តក្នុងការជ្រើសរើសយកប្រធានបទ " បញ្ហាប្រឈមក្នុងការប្រើប្រាស់សៀវភៅសិក្សាគោលភាសាអង់គ្លេសនៅមធ្យមសិក្សាក្នុងខេត្តតាកែវ" មកសិក្សា ពោលគឺក្នុងន័យឆ្លើយតបទៅនឹងតម្រូវការសង្គមសិក្សានានាក្នុងប្រទេសខ្មែរ។

## ១.២- បញ្ហានៃការស្រាវជ្រាវ

ការអនុវត្តសៀវភៅសិក្សាគោលភាសាអង់គ្លេសនៅតាមមធ្យមសិក្សាទុតិយភូមិគឺជាការអនុវត្តឱ្យស្របតាមកម្មវិធីសិក្សារបស់ក្រសួអប់រំដែលដាក់ចេញនូវគោលនយោបាយក្នុងឆ្នាំនីមួយៗ។ ចំណែកឯសៀវភៅសិក្សាគោលក៏មានការបោះពុម្ពច្រើនដងមកហើយ ពោលគឺក្នុងន័យដើម្បីធ្វើបច្ចុប្បន្នភាពខ្លឹមសារមេរៀន វិធីសាស្ត្របង្រៀន និងសម្ភារបង្រៀនឱ្យកាន់តែប្រសើរឡើង។ ទន្ទឹមនឹងនេះដែរ ចំពោះការយកសៀវភៅសិក្សាគោលទៅប្រើប្រាស់ក្នុងការបង្រៀននូវមិនទាន់មានការឯកភាពគ្នានៅឡើយ បើយើងក្រឡេកមើលទៅតាមសាលាគោលដៅនីមួយៗនោះ។ ជាមួយគ្នានេះដែរ ការសិក្សាស្រាវជ្រាវពីប្រធានបទ "បញ្ហាប្រឈមក្នុងការប្រើប្រាស់សៀវភៅសិក្សាគោលភាសាអង់គ្លេសនៅមធ្យមសិក្សា" នេះ មានបញ្ហាមួយចំនួនដូចខាងក្រោម៖

- ការអនុវត្តសៀវភៅសិក្សាគោលផ្សេងគ្នានាំឱ្យសមត្ថភាពពុទ្ធិរបស់សិស្សមានកម្រិតផ្សេងគ្នា

- ការអនុវត្តផ្ទុយពីកម្មសិក្សាលម្អិតរបស់ក្រសួងអប់រំ ពោលគឺនាំឱ្យមានបញ្ហាចំពោះអ្នកដែលត្រូវបានទទួលសេវាកម្មសិក្សា

- វិធីសាស្ត្របង្រៀននិងសម្ភារបង្រៀនមិនមានទំនើបកម្ម ព្រមទាំងទាញផលជះដល់អ្នកផ្តល់សេវាកម្មផងដែរ។

## ១.៣- គោលបំណងនៃការស្រាវជ្រាវ

### ១.៣.១- គោលបំណង

ចំពោះការសិក្សាស្រាវជ្រាវខាងលើនេះគឺមានគោលបំណងចម្បងមួយចំនួនដែលជាប់ពាក់ព័ន្ធទៅនឹងបញ្ហាប្រឈមក្នុងការប្រើប្រាស់សៀវភៅសិក្សាគោលភាសាអង់គ្លេសនានានៅតាមកវិទ្យាល័យមួយចំនួនក្នុងខេត្តតាកែវ។

គោលបំណងចម្បងៗទាំងនោះគឺមានបំណងដើម្បីនឹងផ្សារភ្ជាប់ទៅនឹងវិស័យអប់រំ ពោលគឺយើងអាចនិយាយបាន ការសិក្សានេះនឹងផ្តោតលើទិដ្ឋភាពមួយចំនួនដូចតទៅៈ

- ស្នេរចង់បង្ហាញនិងស្វែងយល់ទៅលើបញ្ហាប្រឈមក្នុងការអនុវត្តទីទៃពីគ្នាចំពោះសៀវភៅសិក្សាគោលភាសាអង់គ្លេសនៅតាមវិទ្យាល័យនៃខេត្តតាកែវ( នៅកម្រិតមធ្យមសិក្សា )។

- ការកំណត់អត្តសញ្ញាណកម្មពីផលប្រឈមនានាដែលកើតពេលដែលលោកគ្រូ អ្នកគ្រូអនុវត្តសិកក្សាគោលផ្សេងគ្នា

- ដើម្បីស្វែងយល់និងកំណត់អត្តសញ្ញាកម្មពីបញ្ហាប្រឈមនានាក្នុងការអនុវត្តវិធីសាស្ត្របង្រៀន និងសម្ភារបង្រៀនរបស់លោកគ្រូ អ្នកគ្រូ ពោលគឺដើម្បីធ្វើទំនើបកម្មឱ្យស្រប់តាមសង្គមនីយកម្មផងដែរ។

### ១.៣.២- សំណួរស្រាវជ្រាវ

នៅក្នុងការសិក្សាស្រាវជ្រាវប្រធានបទខាងលើ ស្នេរបានចោទនិងឆ្លើយសំណួរ ពោលគឺតបទៅនឹងបញ្ហាប្រឈមនិងគោលបំណងដែលបានពោលរួចមកផងដែរ។ ចំពោះសំណួរគឺសូមបង្ហាញជូនដូចខាងក្រោមនេះ។

១ ) ហេតុអ្វីបានជាលោកគ្រូ អ្នកគ្រូនៅមធ្យមសិក្សាមានការអនុវត្តទៅលើសៀវភៅសិក្សាគោលភាសាអង់គ្លេសមានលក្ខណៈខុសគ្នា ?

២ ) តើសិស្សមានផលវិបាកដូចម្តេចបើលោកគ្រូ អ្នកគ្រូបង្រៀនសៀវភៅសិក្សាគោលភាសាអង់គ្លេសខុសគ្នា ?

៣) តើវិធីសាស្រ្តបង្រៀននិងសម្ភារៈបង្រៀនសៀវភៅទាំងពីរឆ្លើយតបទៅនឹងការអវិឌ្ឍកម្មសិក្សា ពោលគឺនឹងបង្កើតបានមូលធនមនុស្សពេញសម្រាប់ជាតិនាថ្ងៃអនាគតឬទេ?

### ១.៣.៣- សារៈសំខាន់នៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះគឺពិតជាមានសារប្រយោជន៍ និងសារៈសំខាន់សម្បើមណាស់សម្រាប់កម្ពុជរដ្ឋ ជាពិសេសវិស័យអប់រំយើង លោកគ្រូ អ្នកគ្រូ និងអ្នកដែលមានបំណងជ្រើសរើសវិធីស្រាវជ្រាវមួយនេះនៅពេលក្រោយៗទៀត។

ជាចំណុចចម្បងនៅក្នុងនិក្ខេបបទនេះគឺអាចជាប្រយោជន៍ដល់វិស័យអប់រំ ពីព្រោះបញ្ហាប្រឈមនានាក្នុងការអនុវត្តសៀវភៅសិក្សាគោលជាផ្នែកមួយនៃការបង្រៀននិងរៀនរបស់គ្រូ ព្រមទាំងសិស្សានុសិស្សទៀតផង។ ក្នុងន័យនេះ បញ្ហាប្រឈមនានាគឺជាកត្តាកំណត់ពីអត្តសញ្ញាណកម្មនៃអ្នកទទួលសេវាកម្មក្នុងវិស័យនាពេលអនាគតពួកគេថែមទៀត។

ម្យ៉ាងមួយវិញទៀតការសិក្សាអំពីបញ្ហាប្រឈមក្នុងការប្រើប្រាស់សៀវភៅសិក្សាគោលភាសាអង់គ្លេសក៏មានសារៈសំខាន់ក្នុងការសិក្សាស្រាវជ្រាវផងដែរទៅលើបញ្ហាប្រឈមផ្សេងៗទៀតនៅក្នុងវិស័យអប់រំ ពោលគឺជាការបង្ហានូវគោលការមួយចំនួនក្នុងនៃប្រទេសខ្មែរយើង។ ជាការពិតណាស់យើងប្រាកដជារកឃើញនូវវិធីសាស្រ្តសំខាន់ៗដូចបានបង្ហាញនៅក្នុងគោលបំណងសិក្សាខាងលើ ពោលគឺយើងអាចនិយាយបាន វាជាការបង្ហាញនូវគោលការណ៍ដល់ការសិក្សាពីបញ្ហាប្រឈមនានាក្នុងការអនុវត្តសៀវភៅសិក្សាគោលក្នុងកម្មវិធីសិក្សា។

## ១.៤- ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ

### ១.៤.១- ដែនកំណត់នៃការស្រាវជ្រាវ

ដែនកំណត់ គឺជាការកំណត់យកនៅកម្រិត ឬលក្ខខណ្ឌណាមួយដែលអ្នកសិក្សាស្រាវជ្រាវចង់បាន តួយ៉ាងនៅក្នុងការសិក្សាស្រាវជ្រាវនេះគឺពុំបានពិនិត្យមើលទៅលើការអនុវត្តសៀវភៅគ្រប់មុខវិជ្ជានោះទេ ដោយផ្តោតសំខាន់តែទៅលើមុខវិជ្ជាមួយទេគឺ មុខវិជ្ជា ភាសាអង់គ្លេស។ មូលហេតុដែលអ្នកស្រាវជ្រាវជ្រើសរើសមុខវិជ្ជានេះ គឺផ្អែកលើការណែនាំរបស់ក្រសួងអប់រំ យុវជន និងកីឡា បានដាក់ចេញអោយមានការប្រើប្រាស់ទៅលើសៀវភៅសិក្សាគោលភាសាអង់គ្លេសសម្រាប់មធ្យមសិក្សាទុតិយភូមិ។ ហើយម្យ៉ាងទៀតចំពោះការសិក្សានេះផងដែរ និងរកឱ្យឃើញពីបញ្ហាប្រឈមមួយចំនួនក្នុងការអនុវត្តសៀវភៅសិក្សាគោលភាសាអង់គ្លេសនៅមធ្យមសិក្សា ដើម្បីក្លាយជាចំណុចថ្មីៗដែលបានរកឃើញសម្រាប់លោកគ្រូ អ្នកគ្រូដែលជាគ្រូដែលបានកំពុងបង្រៀនលើមុខវិជ្ជាភាសាអង់គ្លេស ឬកំពុងអនុវត្តសៀវភៅសិក្សាគោលភាសាអង់គ្លេស ក្នុងការយល់ដឹង និងឆ្លុះបញ្ចាំងអោយឃើញនូវចំណុចដែលខ្លួនខ្វះខាត ព្រមទាំងចំណុចខ្វះខាតរបស់សិស្សផងដែរ និងការជួយពង្រឹង

បន្ថែមទៅលើប្រសិទ្ធភាពក្នុងការអនុវត្តទៅលើសៀវភៅសិក្សាគោលភាសាអង់គ្លេស។ មិនតែប៉ុណ្ណោះក៏ជាមេរៀនឬជាបទពិសោធមួយសម្រាប់ការនាំ និងទ្រួសត្រាយផ្លូវសម្រាប់អ្នករៀបចំកម្មវិធី និងអ្នកអនុវត្តឱ្យស្រេបទៅតាមតម្រូវការបរិបទសង្គម និងការឆ្លើយតបនៃកំណែទម្រង់។ លើសពីនេះទៅទៀត ការសិក្សាមួយនេះក៏បានទុកជាឯកសារ សម្រាប់អ្នកសិក្សាក្រោយៗ។

## ១.៤.២- វិសាលភាពនៃការស្រាវជ្រាវ

វិសាលភាព គឺជាការជ្រើសរើសយកផ្នែក ឬគោលដៅដែលត្រូវចុះ ក្នុងការសិក្សាស្រាវជ្រាវនេះ ជាករណីសិក្សានៅវិទ្យាល័យក្នុងខេត្តតាកែវ ដោយបានជ្រើសរើសយកវិទ្យាល័យធំៗចំនួនបួន និងស្ថិតនៅក្នុងស្រុកចំនួនបីផងដែរ។ វិទ្យាល័យទីមួយគឺវិទ្យាល័យប៊ុនរ៉ានីហ៊ុនសែនបាទីដែលស្ថិតនៅក្នុងស្រុកបាទី ដែលមានអ្នកចូលរួមយកសំណាកចំនួនប្រាំមួយនាក់ ទីពីរវិទ្យាល័យសម្តេចឪ ដែលស្ថិតនៅក្នុងស្រុកសំរោង មានអ្នកចូលរួមយកសំណាកចំនួនប្រាំនាក់ និងវិទ្យាល័យទីបីគឺវិទ្យាល័យភ្នំមាសដែលស្ថិតនៅក្នុងឃុំព្រៃផ្ដៅ ស្រុកព្រៃកប្បាស ដែលមានអ្នកចូលរួមយកសំណាកចំនួនប្រាំមួយនាក់ ទីបួនគឺវិទ្យាល័យហេងសំរិនព្រៃល្វាដែលស្ថិតនៅក្នុងស្រុកព្រៃកប្បាស ដែលមានអ្នកចូលរួមយកសំណាកចំនួនបីនាក់ វិទ្យាល័យដែលបានរៀបរាប់ខាងលើនេះគឺជាសាលាដែលត្រូវចុះទៅប្រមូលទិនន្ន័យដោយផ្ដោតតែការអនុវត្តសៀវភៅសិក្សាគោលភាសាអង់គ្លេសនៅមធ្យមសិក្សាប៉ុណ្ណោះ។

ជារួមមកការសិក្សានេះគឺជាការអនុវត្តសៀវភៅសិក្សាគោលភាសាអង់គ្លេសនៅតាមវិទ្យាល័យមួយចំនួនដែលបានរៀបរាប់ខាងលើ និងឯកសារនានាដែលត្រូវបានយកមកសិក្សាប៉ុណ្ណោះ។

## ១.៥- រចនាសម្ព័ន្ធស្រាវជ្រាវ

នៅក្នុងនិក្ខេបបទនេះបែងចែកជាជំពូកដូចតទៅ៖

**ជំពូកទី១៖** នៅក្នុងសេចក្តីផ្តើម និងក្នុងជំពូកទី១នេះអ្នកសិក្សាស្រាវជ្រាវត្រូវបានលើកឡើងពីចំណុចសំខាន់ដូចជា លំនាំបញ្ហានៃការស្រាវជ្រាវ ចំណោទបញ្ហានៃការស្រាវជ្រាវ សំណួរស្រាវជ្រាវ គោលបំណង និងដែនកំណត់និងវិសាលភាពនៃការសិក្សាស្រាវជ្រាវ។

**ជំពូកទី២៖** រំលឹកទ្រឹស្តីនៅក្នុងជំពូកនេះអ្នកសិក្សាស្រាវជ្រាវត្រូវប្រមូលទ្រឹស្តីពីអ្នកសិក្សាស្រាវជ្រាវមុនៗដែលពាក់ព័ន្ធទៅនឹងប្រធានបទដែលខ្លួនបានសរសេរ ដើម្បីធ្វើជាគំនិតសម្រាប់ធ្វើការស្រាវជ្រាវ និងបង្កើតស្នាដៃថ្មី ។

**ជំពូកទី៣៖** វិធីសាស្ត្រស្រាវជ្រាវនៅក្នុងជំពូកនេះផងដែរអ្នកសិក្សាស្រាវជ្រាវត្រូវបង្ហាញនូវឧបករណ៍ស្រាវជ្រាវដែលជាវិធីសាស្ត្រក្នុងការប្រមូលទិន្នន័យ វិធីជ្រើសរើសសំណាក និងវិធីសាស្ត្រក្នុងការវិភាគទិន្នន័យផងដែរ ។

**ជំពូកទី៤៖** ការនិយាយអំពីព័ត៌មានដែលទាក់ទងទៅនឹងខេត្តតាកែវ ព្រមទាំងទិដ្ឋភាព និងទីតាំងនៃវិទ្យាល័យមួយចំនួនដែលស្ថិតនៅក្នុងខេត្តតាកែវ។

**ជំពូកទី៥៖** បន្ទាប់ពីទទួលបានលទ្ធផល និងការពិភាក្សា នៅក្នុងជំពូកនេះរួច អ្នកសិក្សាស្រាវជ្រាវត្រូវយក ទិន្នន័យដែលប្រមូលបានមកវិភាគ និងធ្វើការបកស្រាយយ៉ាងក្បោះក្បាយ ដើម្បីរកឱ្យឃើញ នូវកម្រិតយល់ដឹង ការអនុវត្ត បញ្ហាប្រឈម និងទស្សនៈយល់ឃើញជារួម ។

**ជំពូកទី៦៖** នៅក្នុងជំពូកទី៦ ជាពេលដែលអ្នកសិក្សាស្រាវជ្រាវធ្វើ សេចក្ដីសន្និដ្ឋាន និងសំណូមពរ ជាផ្នែកមួយទៀតដែលអ្នកសិក្សាស្រាវជ្រាវត្រូវធ្វើការសន្និដ្ឋានទៅលើចំណុចទាំងអស់ដែលបានយកមកវិភាគ ព្រមទាំងផ្ដល់ជាសំណូមពរខ្លះៗក្នុងគោលបំណងចូលរួមចំណែក ធ្វើឱ្យការអនុវត្តការសិក្សាស្រាវជ្រាវមេរៀនប្រសើរឡើងថែមទៀត។

# ជំពូក២
# រម្លឹកទ្រឹស្តី

# ជំពូក២
# រំលឹកទ្រឹស្ដី

## ២.១- និយមន័យនៃពាក្យគន្លឹះ

### ២.១.១- បញ្ហាប្រឈម

វចនានុក្រមខ្មែរ(១៩៦៧) បានពន្យល់ន័យទៅលើពាក្យ "បញ្ហា" ដែលជាពាក្យមកពីបាលីសំស្ក្រឹតនិងមានថ្នាក់ពាក្យជានាម ដែលមានន័យថា ពាក្យឬទីសេចក្ដីដែលមានអាថ៌កំបាំង លុះត្រាតែអ្នកមានប្រាជ្ញាវាងវៃទើបអាចដឹង ឬលុះត្រាសួរអ្នកចេះ ទើបអាចដឹងច្បាស់បាន, ប្រស្នា, ចំណោទ, ដោះស្រាយបញ្ហា។ ចំពោះពាក្យ "ប្រឈម" មានថ្នាក់ពាក្យជាកិរិយាសព្ទដែលមានន័យថា ឈមមុខបែរកគ្នា, ប្រឈមមុខគ្នា, អង្គុយប្រឈមមុខរកគ្នា។

### ២.១.២- សៀវភៅសិក្សាគោល

វចនានុក្រមខ្មែរ(១៩៦៧) បានពន្យល់ន័យរបស់ពាក្យ "សៀវភៅ" ដែលមានថ្នាក់ពាក្យជានាមសព្ទ និងមានន័យថា ប្រជុំក្រដាសដែលដេរកាត់ស្រេច មានទំហំនិងកម្រាស់តាមការប្រកបមានក្របពីខាងក្រៅ, សម្រាប់ប្រើការសរសេរកត់ត្រា ឬដែលសរសេរ, ដែលបោះពុម្ពហើយ: សៀវភៅសរសេរ, សៀវភៅបញ្ជី, សៀវភៅបញ្ជូន, សៀវភៅបោះពុម្ព ឬសៀវភៅពុម្ព។ល។ រីឯពាក្យ "សិក្សា" គឺជាពាក្យមកពី(សំស្ក្រឹត: គិក្សា និងបាលី: សិក្ខា) ដែលមានថ្នាក់ពាក្យជានាមសព្ទ និងមានន័យថា សិក្ខា គឺការរៀន; ការរៀនទន្ទេញ; ការសូត្ររៀន; ការហ្វឹក; ការហ្វឹកហាត់; ការប្រុងប្រយ័ត្នរក្សាមាយាទឱ្យល្អ ខំប្រតិបត្តិ; វិជ្ជា; ការស្ទាត់ជំនាញ....។ ចំពោះពាក្យ "គោល" មកពីសំស្ក្រឹតផង និងមកពីភាសាបាលីផង និងមានថ្នាក់ពាក្យជានាមសព្ទ ដែលមានន័យថា គោល ឬគោលក "ដុំ, ដុំមូល, មណ្ឌល; កូនគ្លី..." ) ដុំថ្ម; ដុំដែក; ដុំ ឬកំណាត់ឈើ; ឬក៏ដុំផ្ទាំងដែលរៀបឥដ្ឋទោះមានចារឹកអក្សរក្ដី មិនមានអក្សរក្ដីដែលគេដឹកដាំ ឬបោះទុកជាគ្រឿសំគាល់ឱ្យដឹងព្រំប្រទល់ជាដើម: បោះគោល, គោលវត្ត, គោលសេចក្ដី, គោលចម្ការ គោលខេត្ត គោលព្រំដែន។

### ២.១.៣- ភាសាអង់គ្លេស

វចនានុក្រមខ្មែរ(១៩៦៧) បានពន្យល់ន័យនៃពាក្យ " ភាសា" ពាក្យនេះមកពីពាក្យបាលីសំស្ក្រឹត ដែលមានថ្នាកពាក្យជានាមសព្ទ និងមានន័យថា សម្ដី; ពាក្យ; ភាសាសំស្ក្រឹត, ភាសាបាលី, ភាសាជាតិ, ភាសាបរទេស។ល។ រីឯពាក្យ "អង់គ្លេស" មានន័យថា(ម.ព. អងគ្លេស)។

សហគមន៍សេដ្ឋកិច្ចអាស៊ាន(ASEAN economic community (AEC)) ទើបតែបង្កើតឡើងថ្មីៗនៅចុងឆ្នាំ ២០១៥ បានកំណត់ថា ភាសាអង់គ្លេសជាភាសាសម្រាប់ទំនាក់ទំនងសម្រាប់បណ្ដាប្រទេសនៅអាស៊ីអាគ្នេយ៍។

បន្ទាប់ពីយើងបានពន្យល់ន័យនៃពាក្យគន្លឹះនីមួយៗរួចមក យើងអាចទាញសេចក្តីសន្និដ្ឋានបានថាបញ្ហាប្រឈមក្នុងការប្រើប្រាស់សៀវភៅសិក្សាគោលភាសាអង់គ្លេសគឺមានន័យថា ការប្រឈម ឬឧបសគ្គរាំងស្ទះក្នុងដំណើរការនៃការអនុវត្តសៀវភៅសិក្សាគោលភាសាអង់គ្លេសនៅមធ្យមសិក្សា។

## ២.២- សាវតាការអនុវត្តសៀវភៅសិក្សាគោលភាសាអង់គ្លេស

ភាសាអង់គ្លេស ជាភាសាមួយដែលត្រូវបានប្រើប្រាស់សម្រាប់ទំនាក់ទំនង និងជាភាសាទីពីរដែលត្រូវបានប្រើប្រាស់នៅលើពិភពលោក ដោយឃើធនធានមនុស្សជាកត្តាមួយដ៏សំខាន់ក្នុងការអភិវឌ្ឍសង្គមជាតិអោយទទួលបានជោគជ័យ។ នៅក្នុងគោលដៅចម្បងរបស់ផែនការអភិវឌ្ឍន៍សង្គមកិច្ចគឺជាការរៀបចំ និងធ្វើឱ្យប្រជាជនប្រែក្លាយជាពលរដ្ឋពេញលេញមានជំនាញវិជ្ជាជីវៈច្បាស់លាស់ ព្រមទាំងពោរពេញទៅដោយសមត្ថពុទ្ធិផងដែរ។

ដោយមើលឃើញពីភាពចាំបាច់ និងសារៈសំខាន់នៃភាសាអង់គ្លេសមួយនេះ ទើបក្រសួងអប់រំ យុវជន និងកីឡាបានដាក់បញ្ចូលមុខវិជ្ជាភាសាអង់គ្លេសទៅក្នុងកម្មវិធីសិក្សាតាំងពីឆ្នាំ១៩៩៣មកម្ល៉េះ ក្នុងគោលបំណងដើម្បីបញ្ជ្រាបការយល់ដឹង និងបណ្តុះធនធានមនុស្សនៅក្នុងប្រទេសអោយមានសម្តតភាព គុណភាពក្នុងការអភិវឌ្ឍសង្គម និងមានការប្រកួតប្រជែងនិងប្រទេសដទៃ ក្នុងការដឹកនាំប្រទេស និងសង្គមឱ្យមានភាពរីកចម្រើន និងឆ្ពោះទៅរកបច្ចេកវិទ្យាហើយនិងបរិបទរបស់សង្គម។

ក្រសួងបានយកចិត្តទុកដាក់ទៅលើធមធានមនុស្សជាខ្លាំង ព្រោះធនធានមនុស្សជាកត្តាចាំបាច់ក្នុងការអភិវឌ្ឍប្រទេសជាតិ និងដឹកនាំប្រទេសឆ្ពោះទៅរកឧត្តមភាព និងការរីកចម្រើនលើគ្រប់វិស័យ។ ដើម្បីអោយធនធានមនុស្សមានគុណភាព និងសមត្ថភាព ព្រមទាំងជំនាញដែលពោរពេញទៅដោយចំណេះដឹង និងច្ចេកវិទ្យា ភាសាផងនោះ ទើបមានការដាក់បញ្ចូលភាសាអង់គ្លេសទៅក្នុងប្រព័ន្ធអប់រំនៅក្នុងប្រទេសកម្ពុជានៅគ្រប់កម្រិតសិក្សា។

ដំបូងឡើយកម្មវិធីសិក្សាភាសាអង់គ្លេសត្រូវបានដាក់ឱ្យសិក្សាតែនៅក្នុងវិទ្យាល័យទេ ដោយហេតុថានៅវិទ្យាល័យ ជាថ្នាក់មួយដែលត្រូវបន្តទៅលើជំនាញបន្ទាប់ពីចប់ទៅ បែបនេះហើយទើបភាសាអង់គ្លេសត្រូវបានបញ្ចូលក្នុងកម្មវិធីសិក្សា រហូតមកដល់បច្ចុប្បន្ន ព្រមទាំងបានធ្វើកំណែទម្រង់ទៅលើមុខវិជ្ជានេះផងដែរ។

ដោយហេតុនេះហើយ ដើម្បីឆ្លើយតបទៅនិងបរិបទថ្មីនេះ វិស័យអប់រំក៏បានធ្វើកំណែទម្រង់ផងដែរ ដើម្បីធានាបាននូវគុណភាព ប្រសិទ្ធភាព ដោយបានធ្វើការអភិវឌ្ឍកម្មវិធីសិក្សា និង

សៀវភៅសិក្សាគោលនេះជាចំណុចអាទិភាពមួយក្នុងចំណោមកំណែទម្រង់ទាំងដប់ប្រាំរបស់ក្រសួងអប់រំ ទៅលើគ្រប់កម្រិតភូមិសិក្សាចាប់ពីមតេយ្យរហូតទៅដល់មធ្យមសិក្សា។

ដោយឡែក កម្មវិធីសិក្សាលម្អិតលើមុខវិជ្ជាភាសាអង់គ្លេសនៅកម្រិតមធ្យមសិក្សាទុតិយភូមិថ្មីនេះ ដោយផ្អែកទៅលើក្របខណ្ឌកម្មវិធីសិក្សាចំណេះទូទៅ និងអប់រំបច្ចេកទេសនៅក្នុងឆ្នាំ ២០១៦ តម្រូវអោយមានការកែលម្អទៅលើខ្លឹមសារសំខាន់ៗ ទាំងលទ្ធផលរំពឹងទុក ទាំងរបាយម៉ោង ការអនុវត្ត វិធីសាស្ត្របង្រៀន និងការវាយតម្លៃ ថែមទាំងបានបន្ថែមម៉ោងសិក្សាច្រើនជាងមុននៅក្នុងកម្មវិធីទៀតផង។ កម្មវិធីសិក្សាលម្អិតភាសាអង់គ្លេសនេះបានបែងចែកជាបីភូមិសិក្សាដាច់ដោយឡែកពីគ្នា ប៉ុន្តែមានទំនាក់ទំនង និងគាំទ្រគ្នាទៅតាមកម្រិតមួយៗ។ ដោយការធ្វើកំណែទម្រង់កម្មវិធីសិក្សានៅកម្រិតមធ្យមសិក្សាទុតិយភូមិនេះ គឺសំដៅទៅលើការអប់រំនៅកម្រិតទុតិយភូមិដោយពង្រីកវិសាលភាពចំណេះដឹង បំណិន ការអប់រំសីលធម៌ បច្ចេកវិទ្យា និងបំណិនសតវត្សទី ២១ផងដែរ។

មិនតែប៉ុណ្ណោះក្រសួងក៏បានធ្វើកំណែទម្រង់កម្មវិធីលម្អិតភាសាអង់គ្លេសនៅមធ្យមសិក្សាបឋមភូមិ និងកម្រិតបឋមសិក្សាផងដែរ ដោយបានបន្ថែមចំនួនម៉ោងសិក្សាច្រើនជាងមុន ដើម្បីអោយការអប់រំជាមូលដ្ឋានសម្រាប់អ្នកសិក្សា បង្កើនគុណភាព និងប្រសិទ្ធភាព ដល់អ្នកសិក្សាអោយមានបំណិនសម្បទា និងជំនាញ ដើម្បីអាចទៅបន្តការសិក្សា និងទទួលការបណ្តុះបណ្តាលផ្សេងៗទៀត កាន់តែទទួលបានជោគជ័យ។

ដោយហេតុនេះហើយទើបក្រសួងបានធ្វើការកែទម្រង់កម្មវិធីសិក្សាភាសាអង់គ្លេស ដើម្បីឆ្លើយតបទៅនិងបរិបទថ្មីក្នុងការអនុវត្តអោយមានប្រសិទ្ធភាព និងគុណភាព ទាំងបំណិនសម្បទាកម្រិតជំនាញ ទាំងបច្ចេកវិទ្យា និងចំណេះដឹង ដើម្បីទទួលបានជោគជ័យនៅក្នុងសង្គម។

ការមើលឃើញពីភាពចាំបាច់ទាំងអស់នេះហើយដែលធ្វើអោយក្រសួងអប់រំ កាន់តែយកចិត្តទុកដាក់ខ្លាំងឡើងៗរហូត បញ្ចូលភាសាអង់គ្លេសទៅក្នុងកម្មវិធីសិក្សានៅអនុវិទ្យាល័យបន្ថែមទៀតដើម្បីលើកស្ទួយធនធានមនុស្សឱ្យកាន់តែមានគុណភាព និងសមត្ថភាពជាងមុន ម្យ៉ាងក៏អាចផ្តល់ឱកាសដល់សិស្សានុសិស្សបានសិក្សាបន្ថែម និងទទួលបានចំណេះដឹងខាងភាសាកាន់តែទូលំទូលាយ ដើម្បីជាទុនក្នុងការចាប់យកមុខវិជ្ជានេះនៅថ្នាក់វិទ្យាល័យ។ មិនតែប៉ុណ្ណោះការដាក់មុខវិជ្ជានេះនៅមធ្យមសិក្សាបឋមភូមិ នឹងបានផ្តល់ជាប្រយោជន៍ដល់សិស្សានុសិស្សកម្ពុជាទទួលបាននូវបំណិនទំនាក់ទំនង ដោយប្រើភាសាអន្តរជាតិមួយនេះក្នុងវិស័យវប្បធម៌ បច្ចេកវិទ្យា វិទ្យាសាស្ត្រដើម្បីបន្តការសិក្សានៅមធ្យមសិក្សាទុតិយភូមិ ឬឧត្តមសិក្សាលើមុខជំនាញផ្សេងៗ។

ដោយកាន់តែមានភាពចាំបាច់ដោយខានមិនបាន នៅឆ្នាំ២០១៣ ក្រសួងអប់រំ បានដាក់បញ្ចូលការអប់រំភាសាអង់គ្លេសនៅកម្រិតបឋមសិក្សាមួយកម្រិតទៀត ដោយរំពឹងថាការដាក់បញ្ចូលភាសាអង់គ្លេសនៅកម្រិតបឋមសិក្សា និងជួយពង្រឹងបន្ថែមទៅលើសមត្ថភាព ពោលគឺសំដៅដលើការបណ្តុះបណ្តាល អំពីបុគ្គលិកលក្ខណៈរបស់អ្នកសិក្សាឱ្យមានភាពពេញលេញ ទាំងផ្នែកបញ្ញាស្មារតី សម្រាប់អ្នកសិក្សាក្នុងការអភិវឌ្ឍខ្លួន និងត្រៀមក្នុងការទទួលយកចំណេះដឹងដើម្បីបន្តទៅសិក្សានៅកម្រិតអនុវិទ្យាល័យ ឬកម្រិតវិទ្យាល័យ ដែលធ្វើឱ្យអ្នកសិក្សាមាន បញ្ញា តម្លៃ សមត្ថភាព និងបំណិននៅក្នុងខ្លួន និងក្លាយទៅជាធនធានមនុស្សដ៏មានប្រយោជន៍សម្រាប់ខ្លួនឯង សង្គម គ្រួសារ ដើម្បីជួយប្រទេសជាតិមានការរីកចម្រើនទាន់បរិបទថ្មីរបស់សង្គម។

ជារួមមក ដោយឃើញថាមុខវិជ្ជាភាសាអង់គ្លេសពិតជាមានសារប្រយោជន៍ ក្នុងការចូលរួមចំណែកក្នុងការបណ្តុះបណ្តាលធនធានមនុស្ស ទើបត្រូវបានដាក់ទៅក្នុងកម្មវិធីសិក្សាគ្រប់កម្រិត ដើម្បីជួយដល់ការពង្រឹងគុណភាព សមត្ថភាពរបស់អ្នកសិក្សាទាំងផ្នែកចំណេះដឹង សុជីវធម៌ បច្ចេកវិទ្យា បំណិនដែលធ្វើអោយអ្នកសិក្សាក្លាយទៅជាមនុស្សពេញលេញ ជាធនធានដែលសង្គមត្រូវការក្នុងការដឹកនាំប្រទេសឱ្យមានភាពរីកចម្រើនតាមបច្ចេកវិទ្យាទំនើបរបស់សង្គម។

## ២.៣- ទស្សនៈផ្សេងៗនៃបញ្ហាប្រឈមក្នុងការប្រើប្រាស់សៀវភៅសិក្សាគោលភាសាអង់គ្លេស

ចំពោះការអនុវត្តទៅលើសៀវភៅសិក្សាគោលភាសាអង់គ្លេស ដោយសារសៀវភៅសិក្សាគោល មានលក្ខណៈមួយថាហួសកម្រិតនៃចំណេះដឹងរបស់សិស្ស ធ្វើអោយឲ្យការអនុវត្តសៀវភៅពុំសូវទទួលបានលទ្ធផលល្អ ធម្មតាសិស្សនៅតាមជនបទពុំសូវបានរៀនដូចសិស្សនៅតាមទីក្រុង ចំណេះដឹងមានលក្ខណៈមិនដូចគ្នាទេ ពេលយកទៅអនុវត្តមានការពិបាក ដោយចំណាយពេលវេលាច្រើន ការអនុវត្តមានភាពយឺតយ៉ាវ មិនទទួលបានដូចការរំពឹងទុក។

**ទូត វាសនា** (២០១៤-២០១៦:57) ទោះជាយ៉ាងណាក្តីយើងក៏ឃើញមានបញ្ហាផ្សេងៗទៀតក្នុងការប្រើប្រាស់សៀវភៅសិក្សាគោល និងម្យ៉ាងវិញទៀតក៏ឃើញថា ថ្នាក់ដឹកនាំសាលាដែលរួមមានទាំងនាយកសាលា នាយករង នាយិការង បណ្ណារក្ស និងគ្រូដែលទទួលបានបានការណែនាំពីក្រសួងអប់រំក្តី គឺនៅមានបញ្ហា និងចំណុចខ្វះខាតច្រើនទៀតនៅតាមវិទ្យាល័យនីមួយៗ។ ដោយមើលឃើញនូវចំណុចទាំងអស់នេះហើយ ទើបកត្តាទាំងអស់នេះគឺជា បញ្ហាដែលបណ្តាលមកពីកត្តាដូចជា៖

នៅតាមសាលានីមួយៗមានការខ្វះខាតសម្ភារ និងទីកន្លែងសម្រាប់ទុកដាក់សៀវភៅឱ្យបានត្រឹមត្រូវ ទុកសៀវភៅពាសវាលពាសកាល ដែលជាហេតុធ្វើឱ្យសៀវភៅរខូច រហែក ឬបាត់ ទោះជាបានដាក់វិធានការឱ្យសិស្សមានការថែទាំឬសិស្សធ្វើបាត់សៀវភៅក៏ដោយក៏ហាត់ដូចជាពុំសូវមានប្រសិទ្ធភាព គឺនៅតែមានការបាត់បង់សៀវភៅ ឬខូច រហែកជារៀងរាល់ឆ្នាំ។ កត្តាមួយវិញទៀត គឺការផ្លាស់ប្តូរបណ្ណារក្ស ឬប្តូរបណ្ណាល័យ ញឹកញាប់ពេកក៏ធ្វើឱ្យមានការបាត់សៀវភៅ ឬខូចខាតផងដែរ ដោយសារបណ្ណារក្សគាត់ពុំសូវមានបទពិសោធ និងមិនបានទទួលការបណ្តុះបណ្តាលពីជំនាញក្នុងការគ្រប់គ្រង រៀបចំបណ្ណាល័យ ដូច្នេះបណ្ណារក្សនៅមានការខ្វះចន្លោះច្រើនក្នុងការគ្រប់គ្រងសៀវភៅ និង ទាំងការទុកដាក់ ទាំងការប្រមូលសៀវភៅពីសិស្សវិញ ទាំងរៀបចំ។ ថែមពីនេះទៅទៀត មិនថាគ្រូបង្រៀន ឬសិស្សដែលជាអ្នករៀននោះទេ គឺបានពឹងផ្អែកទាំងស្រុងក្នុងការប្រើប្រាស់សៀវភៅសិក្សាគោលក្នុងការបង្រៀន និងរៀន សម្រាប់ធ្វើជាឧបករណ៍ ឬធ្វើជាសម្ភារក្នុងការបង្រៀន និងរៀន ឬស្រាវជ្រាវមេរៀនជាដើម ដែលទាំងអស់នេះគឺជាភាពចាំបាច់ និងមានសារប្រយោជន៏ចំពោះការប្រើប្រាស់សៀវភៅសិក្សាគោល ដែលគ្រូ និងសិស្សត្រូវការចាំបាច់ដែលមិនអាចខ្វះបានឡើយ។ ចំណុចមួយទៀតការទទួលសៀវភៅសិក្សាគោលរបស់សិស្សក៏ពុំទាន់ទទួលបានគ្រប់គ្រាន់នៅឡើយទេ យ៉ាងណាមិញ ទាក់ទងទៅនឹងសៀវភៅសិក្សាគោលភាសាអង់គ្លេស គឺនៅមានខ្វះខាតច្រើនដែលធ្វើអោយសិស្សពិបាកក្នុងការសិក្សា ដោយខ្វះសៀវភៅសិក្សាគោល ថែមទាំងជាសៀវភៅភាសាអង់គ្លេសទៀត ជាភាសាបរទេសទើបធ្វើឱ្យសិស្ស ឬអ្នកសិក្សាពិបាកក្នុងការយល់ខ្លឹមសារមេរៀន ហើយធ្វើអោយសិស្សពុំយល់ពីតម្លៃនៃសៀវភៅ ទើបមិនបានថែរក្សាសៀវភៅបានល្អសម្រាប់អ្នកក្រោយទៀត។ ដោយមើលឃើញទៅលើកត្តាទាំងអស់នេះហើយដែលធ្វើអោយមានបញ្ហាក្នុងការប្រើប្រាស់សៀវភៅសិក្សាគោល ទាំងការបង្រៀន និងរៀនមួយផ្នែកដែរសម្រាប់គ្រូនិងសិស្ស។

**លោក ថៃ ណាគ្រី** (២០១៨-២០២០: ៥២) បាននិយាយថា ការប្រើប្រាស់សៀវភៅសិក្សាគោលភាសាអង់គ្លេសនៅមានកម្រិតអវិជ្ជមានខ្លាំង ដោយសារលានៅខ្វះសម្ភារទ្រទ្រង់ចាំបាច់មួយចំនួន ជាពិសេសសៀវភៅសិក្សាគោលភាសាអង់គ្លេសមិនសូវបានប្រើទៅតាមខ្លឹមសារមេរៀន ឬសៀវភៅប៉ុន្មានទេ ដោយសារសិស្សមានសមត្ថភាពទាបជាង ចំពោះបណ្ណាល័យមិនសូវមានសៀវភៅដែលទាក់ទងទៅនិងសៀវភៅភាសាអង់គ្លេស សម្រាប់សិស្សអាន ឬសិក្សាស្រាវជ្រាវបន្ថែមចំណេះដឹងផ្នែកភាសាអង់គ្លេស ដូច្នេះសិស្សខ្សោយភាសាពិបាកក្នុងការបង្រៀន និងរៀន ទើបជាកត្តាមួយប្រឈមការអនុវត្តសៀវភៅសិក្សាគោលភាសាអង់គ្លេសឱ្យទទួលបានលទ្ធផលល្អ និងជោគជ័យទៅតាមការដៅទុក។ ម្យ៉ាងវិញទៀតចំពោះគ្រូបង្រៀនផងដែរ ដោយគាត់ពុំសូវបានបង្កើត

សម្ភារឧបទេស សម្រាប់ការបង្រៀនដើម្បីងាយស្រួលក្នុងការយល់ខ្លឹមសារមេរៀន ក្នុងការជួយសិស្សឱ្យឆាប់យល់និងចាប់បានខ្លឹមសារមេរៀនប៉ុន្មានទេ។ ដោយហេតុនេះហើយទើបធ្វើឱ្យការអនុវត្តសៀវភៅសិក្សាគោលមានលក្ខណៈល្អនៅឡើយទេ ដោយសាចំនួននៃមេរៀននៅក្នុងសៀវភៅសិក្សាគោល និងសកម្មភាពដែលគ្រូត្រូវបង្រៀនមិនសូវសមាមាត្រទៅនិងម៉ោងបង្រៀន និងរៀនក្នុងមួយសប្តាហ៏ ពោលគឺចំនួនមេរៀនច្រើន ហើយមេរៀននីមួយៗ ពុំសូវច្បាស់លាស់ទេ ថាជំនាញអីឡើយ អញ្ចឹងហើយទើបជាបញ្ហាប្រឈមក្នុងការអនុវត្តសៀវភៅសិក្សាគោលនៅមានចំណុចខ្វះខាតច្រើនដោយសារបញ្ហាខាងលើនេះ។

តាមប្រសាសន៏របស់ **សៀង គឹមឈឿន** (២០១៧-២០១៩: ៧៥) ការអនុវត្តសៀវភៅសិក្សាគោលគឺនៅមានកម្រិតសមល្មម មិនទាន់មានភាពល្អប្រសើរនៅឡើយទេ ដោយសារសៀវភៅសិក្សា មិនទាន់មានគ្រប់គ្រាន់ ម្យ៉ាងទៀតសៀវភៅសិក្សាគោលមិនទាន់សមាមាត្រទៅនឹងចំនួនម៉ោងដែលត្រូវសិក្សា មេរៀននីមួយៗវែង ហើយច្រើន ដូចនេះគ្រូពិបាកក្នុងការធ្វើបំណែងចែកលម្អិតសម្រាប់បង្រៀនទៅតាមនិយាមម៉ោងដែលបានដាក់ជូនគ្រូអនុវត្ត។

សរុបបញ្ហាខាងលើមក ឃើញថាមានកត្តាជាច្រើនដែលបានធ្វើអោយក្លាយទៅជាបញ្ហាប្រឈមក្នុងការអនុវត្តសៀវភៅសិក្សាគោលភាសាអង់គ្លេសនៅមធ្យមសិក្សា ទាំងអស់នេះជាបញ្ហាដែលបានរកឃើញនៅតាមវិទ្យាល័យនានា នេះហើយដែលការអនុវត្តសៀវភៅសិក្សាគោលមិនមានភាពរលូន និងទទួលបានជោគជ័យ ដោយសារតែខ្វះសៀវភៅសិក្សាផង ចំនួនមេរៀនច្រើន មេរៀនវែង មិនសមាមាត្រនិងនិយាមម៉ោងដែលត្រូវអនុវត្ត រួមផ្សំជាមួយគ្រូមិនសូវបង្កើតសម្ភារឧបទេសផង សិស្សមិនសូវយល់ខ្លឹមសារមេរៀនផង ទើបជាបញ្ហាប្រឈមដល់ការអនុវត្តសៀវភៅសិក្សាគោលភាសាអង់គ្លេសនៅមធ្យមសិក្សា។

# ជំពូក៣
# វិធីសាស្ត្រស្រាវជ្រាវ

# ជំពូក៣
# វិធីសាស្ត្រស្រាវជ្រាវ

## ៣.១- វិធីសាស្ត្រស្រាវជ្រាវ

វិធីសាស្ត្រស្រាវជ្រាវ គឺជាវិធីដែលអ្នកសិក្សាស្រាវជ្រាវបានប្រើប្រាស់ដើម្បីចុះទៅប្រមូលទិន្នន័យដើម្បីទទួលបានទិន្នន័យពីអ្នកចូលរួមក្នុងការផ្ដល់ព័ត៌មានដែលទាក់ទងទៅនឹងទិន្នន័យដែលអ្នកសិក្សាស្រាវជ្រាវចង់បាន។ ក្នុងការចុះប្រមូលទិន្នន័យនេះ អ្នកសិក្សាអាចមានវិធីសាស្ត្រចំនួនបីដែលអ្នកសិក្សាត្រូវការប្រើដែលរួមមាន វិធីសាស្ត្រតាមបែបគុណវិស័យ វិធីសាស្ត្រតាមបែបបរិមាណវិស័យ និងវិធីសាស្ត្រចម្រុះ ដែលត្រូវប្រើតាមបែបគុណវិស័យផង និងបរិមាណវិស័យផង។

វិធីសាស្ត្រតាមបែបគុណវិស័យ ជាសកម្មភាព ដែលកំណត់ទីតាំងអ្នកសិក្សាឱ្យនៅក្នុងពិភពមួយដែលរួមមានសកម្មភាពបកប្រែ សកម្មភាពជាក់ស្ដែង ដែលធ្វើឱ្យសង្គមមួយមានជារូបរាងមក។ ពិភពលោកមួយត្រូវបានបង្ហាញតាមរយៈការកត់ត្រាសម្ដី មូលដ្ឋាននៃពិភពលោកនោះ។ ទើបបានជាការសិក្សាតាមបែបគុណវិស័យ រួមមានវិធីសាស្ត្របកប្រែ និងវិធីសាស្ត្រធម្មជាតិ គឺមានន័យថាអ្នកស្រាវជ្រាវគឺសិក្សាពីវត្ថុនៅក្នុងបរិបទ ឬ ស្ថានភាពនៃវត្ថុនោះក្នុងគោលដៅធ្វើឱ្យវត្ថុនោះមានអត្ថន័យ( Denzin & Lincoln,2005, p.3 ).

ការស្រាវជ្រាវលើប្រធានបទនេះ អ្នកការស្រាវជ្រាវបានប្រើវិធីស្រាវជ្រាវតាមបែគុណវិស័យ។ ការស្រាវជ្រាវតាមបែបគុណវិស័យគឺមានគោលបំណងសិក្សាលើទស្សនៈយល់ឃើញ បញ្ហាប្រឈមផ្សេងៗដែលមាន និងដំណោះស្រាយទៅលើបញ្ហាទាំងនោះហើយម្យ៉ាងទៀត ក្នុងដំណើរការអនុវត្តកម្មវិធីនេះ ដើម្បីឲ្យអ្នកស្រាវជ្រាវបានដឹង និងយល់ច្បាស់ពីឫសគល់ និងហេតុផលទាំងឡាយ និងទស្សនៈផ្ទាល់ខ្លួនពីអ្នកចូលរួមនៅក្នុងការអនុវត្តសៀវភៅសិក្សាគោលភាសាអង់គ្លេសនៅមធ្យមសិក្សាក្នុងខេត្តតាកែវ។

## ៣.២- ការជ្រើសរើសភាគសំណាក

ការជ្រើសរើសភាគសំណាកគំរូ គឺជាការជ្រើសរើសចំនួនអ្នកដែលត្រូវឆ្លើយដើម្បីផ្ដល់ព័ត៌មាន ឬផ្ដល់ទិន្នន័យដល់អ្នកស្រាវជ្រាវ ដើម្បីធ្វើការវិភាគដែលមានការពាក់ព័ន្ធទៅនិងការស្រាវជ្រាវ ភាគសំណាកគំរូនេះគឺត្រូវបានកំណត់ចំនួនទៅតាមអ្នកសិក្សាស្រាវជាវ ដើម្បីទទួលបានទិន្នន័យយកទៅវិភាគ ដោយហេតុនេះហើយទើបអ្នកសិក្សាបានធ្វើការជ្រើសរើសភាគសំណាកដែលត្រូវយកមកវិភាគបានកំណត់យកចំនួន គ្រូ១៦នាក់ និងនាយកសាលាចំនួន០៤នាក់ដែលស្ថិតនៅក្នុងស្រុកចំនួន០៣ និងសាលារៀនចំនួន០៤ ដោយត្រូវយកស្រុកបាទីចំនួន០១សាលា ស្រុកព្រៃក្បាសចំនួន០២សាលា ស្រុកសំរោង០១សាលា ដើម្បីយកមកធ្វើការស្រាវជ្រាវលើប្រធាន

បទនេះ គឺអ្នកសិក្សាស្រាវជ្រាវបានជ្រើសរើសតាមគោលដៅដែលបានកំណត់ទុក ដោយសំដៅយកតែភាគសំណាកទាំងឡាយណា ដែលអ្នកស្រាវជ្រាវពិតជាជឿជាក់ថា ភាគសំណាកទាំងអស់នោះអាចទទួលបាននូវទិន្នន័យបានជាក់លាក់ ច្បាស់លាស់ ដែលនិងអាចឆ្លើយតបទៅនឹងប្រធានបទនេះបាន។ ដូចនេះភាគសំណាកដែលអ្នកសិក្សាស្រាវជ្រាវយល់ថា អាចផ្តល់បាននូវទិន្នន័យទាំងនោះរួមមាន៖ នាយកសាលាចំនួន០១រូប លោកគ្រូ អ្នកគ្រូនៅវិទ្យាល័យភ្ញីមាសចំនួន ៥នាក់ វិទ្យាល័យបាទី លោកនាយកចំនួន០១រូប លោកគ្រូ អ្នកគ្រូចំនួន ៥នាក់ វិទ្យាល័យសម្តេចឪ នាយកសាលាចំនួន០១រូប លោកគ្រូ អ្នកគ្រូចំនួន ៤នាក់ និងវិទ្យាល័យហេងសំរិនព្រៃល្វា នាយកសាលា ០១រូប លោកគ្រូ អ្នកគ្រូចំនួន ២នាក់ សរុបទាំងអស់ ចំនួន២០ នាក់ទាំងអស់នេះសុទ្ធតែជាសំណាកដែលត្រូវបានជ្រើសរើសយកមកដើម្បីធ្វើការវិភាគ ។ នៅក្នុងភាគសំណាកដែលបានជ្រើសរើសទាំងអស់នេះ សុទ្ធតែជាអ្នកដែលបានចូលរួមយ៉ាងសកម្មនៅក្នុងការអនុវត្តសៀវភៅសិក្សាគោលភាសាអង់គ្លេសនៅមធ្យមសិក្សាក្នុងខេត្តតាកែវ ។ ដោយមូលហេតុនេះហើយ ទើបបានជាអ្នកសិក្សាស្រាវជ្រាវជឿជាក់ថា ភាគសំណាកទាំងនេះពិតជាអាចផ្តល់នូវទិន្នន័យ ដែលទាក់ទងទៅនឹងប្រធានបទខាងលើបានជាក់លាក់ និងពិតប្រាកដ ។

## ៣.៣- ឧបករណ៍ស្រាវជ្រាវ

ឧបករណ៍ស្រាវជ្រាវ គឺជាឧបករណ៍ដែលអ្នកសិក្សាស្រាវជ្រាវប្រើប្រាស់ដើម្បីប្រមូលទិន្នន័យ ឬជាកម្រងសំណួរសម្រាប់យកទៅសម្ភាសអ្នកដែលបានផ្តល់ទិន្នន័យសម្រាប់ការសិក្សាលើប្រធានបទអ្វីមួយ។ ដោយហេតុនេះហើយដើម្បីធ្វើឱ្យការស្រាវជ្រាវនេះទទួលបាននៅទិន្នន័យបាន អ្នកស្រាវជ្រាវបានបង្កើតជាកម្រងសំណួរឡើង ដោយផ្អែកលើវត្ថុបំណងនៃការស្រាវជ្រាវ និងទាក់ទងទៅនិងប្រធានបទ ដើម្បីយកទៅសម្ភាសអ្នកដែលបានចូលរួមផ្តល់ទិន្នន័យ។ នៅក្នុងកម្រងសំណួរដែលបានបង្កើតឡើងមកនេះបានបែងចែកមានបួនផ្នែកសំខាន់ គឺ ផ្នែកទីមួយជាការយល់ដឹងលើការអនុវត្តសៀវភៅសិក្សាគោល ដែលបានផ្តោតទៅលើបទពិសោធក្នុងការអនុវត្ត ការផ្តល់និយមន័យ និងគោលបំណងនៃការសិក្សា មួយផ្នែកទៀតគឺគូសរង្វង់ជុំវិញលេខដែលបញ្ជាក់នូវកម្រិតយល់ដឹងរបស់សំណាក និងការគូសលើខ្លឹមសារដែលសំណាកគិតថាយល់ច្បាស់និងមិនទាន់យល់ច្បាស់។ សម្រាប់ផ្នែកទីពីរគឺជាការអនុវត្តសៀវភៅភាសាអង់គ្លេស ដែលឆ្លុះបញ្ចាំងឲ្យឃើញពីការអនុវត្តសៀវភៅសិក្សាគោលភាសាអង់គ្លេសនៅមធ្យមសិក្សាក្នុងខេត្តតាកែវ បង្ហាញពីកម្រិតនៃការចូលរួមរបស់ភាគសំណាក កម្រិតនៃការយល់ស្របរបស់សំណាកលើព័ត៌មានដែលបានផ្តល់ជូនក្នុងការអនុវត្តសៀវភៅ ដោយមានការសរសេររៀបរាប់ពីសកម្មភាពសំខាន់ៗដែលបានអនុវត្តនៅក្នុងសាលាសរសេរបំពេញខ្លឹមសារ ឬសកម្មភាពដែលសំណាកពេញចិត្តនិងងាយអនុវត្ត និងការគូសសញ្ញាធីក

នៅត្រង់ចំណុចដែលសំណាកយល់ថាងាយអនុវត្ត និងយកទៅអនុវត្ត ឬខ្វែងត្រង់ចំណុចដែលគិតថាពិបាកអនុវត្ត និងមិនយកទៅអនុវត្ត។ ចំណែកផ្នែកទីបី គឺស្តីពីបញ្ហាប្រឈមនិងដំណោះស្រាយ ដោយតម្រូវឲ្យសំណាកលើកឡើងពីបញ្ហាប្រឈម និងដំណោះស្រាយ ដែលអាចកើតមានឡើងក្នុងការអនុវត្តសៀវភៅសិក្សាគោលនៅក្នុងការបង្រៀន និងនៅក្នុងសាលា ដូចជា ការអនុវត្តផែនការការចូលរួម ការផ្តល់សម្ភារ ការគាំទ្រពីសាលា បញ្ហាប្រឈមផ្ទាល់ខ្លួន ឬនិងក្រុមមុខវិជ្ជា ឬនិងសាលារៀនទាំងមូលក្នុងការអនុវត្តកម្មវិធី។ ចំណែកផ្នែកទីបួននិយាយអំពីទស្សនៈយល់ឃើញជារួមរបស់ភាគសំណាក មានជាអាទិ៍ ទស្សនៈយល់ឃើញលើការអនុវត្តការសិក្សាស្រាវជ្រាវមេរៀនក្នុងសាលា ការជួយអភិវឌ្ឍវិជ្ជាជីវៈគ្រូបង្រៀន ការជួយអភិវឌ្ឍការបង្រៀននិងរៀន ការជួយអភិវឌ្ឍវិស័យអប់រំនៅកម្ពុជា គំនិតផ្តួចផ្តើមក្នុងការធ្វើឲ្យការអនុវត្តសៀវភៅសិក្សាថ្មីរបស់ក្រសួងនៅក្នុងសាលា កាន់តែប្រសើរឡើង និងសំណូមពរផ្សេងៗ។ កម្រងសំណួរដែលអ្នកស្រាវជ្រាវបានបង្កើតឡើង ដូចបានរៀបរាប់ខាងលើនេះ ត្រូវបានត្រួតពិនិត្យភាពត្រឹមត្រូវយ៉ាងហ្មត់ចត់ និងមានការឯកភាពពីគ្រូណែនាំ។

ទិន្នន័យដែលប្រមូលបានមក គឺជាព័ត៌មានសម្រាប់គាំទ្រដល់ការសិក្សាស្រាវជ្រាវមួយនេះ និងអាចជាព័ត៌មានសម្រាប់ដោះស្រាយបញ្ហាដែលកើតមានឡើងក្នុងការអនុវត្តសៀវភៅសិក្សាគោលភាសាអង់គ្លេសនៅមធ្យមសិក្សាក្នុងខេត្តតាកែវ។ ដើម្បីប្រមូលបាននូវទិន្នន័យដ៏ជាក់លាក់ និងជឿជាក់បាន នោះជាការចាំបាច់ខ្លាំងណាស់ក្នុងការបង្កើតនូវឧបករណ៍ស្រាវជ្រាវនេះឡើង សម្រាប់ប្រមូលទិន្នន័យពីភាគសំណាកដែលបានកំណត់ជ្រើសរើសរួច ក្នុងគោលបំណងដើម្បីស្វែងរកឱ្យឃើញច្បាស់ពីកម្រិតយល់ដឹងជាក់ស្តែងរបស់ពួកគាត់ ពីបញ្ហាប្រឈមក្នុងការប្រើប្រាស់សៀវភៅសិក្សាគោល និងដំណោះស្រាយនានា ដើម្បីឲ្យគណៈគ្រប់គ្រង លោកគ្រូ អ្នកគ្រូ និងអ្នកពាក់ព័ន្ធឆ្លើយតបបានត្រឹមត្រូវទៅ នឹងតម្រូវការជាក់ស្តែងរបស់ពួកគាត់ ព្រមទាំងរកឲ្យឃើញនៅទស្សនៈយល់ឃើញនានារបស់លោកគ្រូអ្នកគ្រូពីបញ្ហាប្រឈមក្នុងការអនុវត្តលើសៀវភៅសិក្សាគោលភាសាអង់គ្លេសនៅមធ្យមសិក្សា ដើម្បីធ្វើជាត្រីវិស័យក្នុងការចង្អុលបង្ហាញផ្លូវ ឆ្ពោះទៅរកការអនុវត្តប្រកបដោយប្រសិទ្ធភាព គុណភាព និងមានចីរភាពលើការអនុវត្តន៏។

## ៣.៤- ការប្រមូលទិន្នន័យ

ក្នុងការស្រាវជ្រាវប្រធានបទខាងលើ អ្នកស្រាវជ្រាវបានប្រមូលទិន្នន័យនិងព័ត៌មានមួយចំនួនពីសៀវភៅ និងឯកសារផ្សេងៗ និងទិន្នន័យដែលបានមកតាមរយៈកម្រងសំណួរសម្ភាស។ ចំពោះទិន្នន័យដែលបានមកពីសៀវភៅនិងឯកសារ អ្នកស្រាវជ្រាវបានដកស្រង់នៅខ្លឹមសារដែលទាក់ទងនឹងប្រធានបទ ដើម្បីយកធ្វើជាឯកសារពិគ្រោះក្នុងការសរសេររៀបរៀងអត្ថបទស្រាវជ្រាវ

ដោយភាគច្រើនមាននៅក្នុងសេចក្ដីផ្ដើម និងរំឭកទ្រឹស្ដី ហើយបានសរសេររៀបរាប់ទៅតាមលំដាប់លំដោយនៃខ្លឹមសារ។ ឯកសារនិងសៀវភៅទាំងនេះមានទាំង ភាសាខ្មែរ និងភាសាអង់គ្លេស ដែលអ្នកស្រាវជ្រាវរកបានពីបណ្ណាល័យ កន្លែងបម្រើការងារ និងទាញយកពីអ៊ីនធឺណែត ដើម្បីធ្វើជាឯកសារផងដែរ។

ម្យ៉ាងទៀត ចំពោះទិន្នន័យដែលទទួលបានមកតាមរយៈកម្រងសំណួរសម្ភាស អ្នកស្រាវជ្រាវបានអនុវត្តទៅតាមជំហានបន្តបន្ទាប់។ ដើម្បីឱ្យដំណើរការចុះប្រមូលទិន្នន័យមានលក្ខណៈជាផ្លូវការ និងដើម្បីឱ្យការប្រមូលទិន្នន័យមានភាពរលូនល្អ អ្នកស្រាវជ្រាវបានយកលិខិតសុំអនុញ្ញាតពីវិទ្យាស្ថានជាតិអប់រំទៅសុំជួបជាមួយថ្នាក់ដឹកនាំមន្ទីរអប់រំ យុវជន និងកីឡាខេត្តតាកែវ និងគណៈគ្រប់គ្រងនៅតាមវិទ្យាល័យដែលអ្នកស្រាវជ្រាវចុះប្រមូលទិន្នន័យ ដើម្បីជម្រាបពីគោលបំណង និងសុំអនុញ្ញាតធ្វើការប្រមូលទិន្នន័យនៅទីតាំង និងភាគសំណាកដែលបានកំណត់ទុករួចជាស្រេច។ អ្នកស្រាវជ្រាវបានស្នើសុំដល់ភាគសំណាកជួយផ្ដល់ទិន្នន័យតាមរយៈសម្ភាស តាមពេលកំណត់ជាក់លាក់ ដោយក្នុងនោះដែរ បន្ទាប់ពីការធ្វើសម្ភាសរួចមក អ្នកស្រាវជ្រាវបានប្រមូល យកទិន្នន័យក្នុងកម្រងសំណួរសម្ភាសមកធ្វើការរៀបរៀងសរសេរតាមវត្ថុបំណងនៃការស្រាវជ្រាវ និងតាមលំដាប់លំដោយខ្លឹមសារ។

នៅក្នុងការប្រមូលទិន្នន័យ អ្នកស្រាវជ្រាវសូមថ្លែងអំណរគុណទៅដល់អ្នកដែលត្រូវបានចូលរួមក្នុងការសម្ភាសន៍ ក្នុងបរិយាកាសស្និទ្ធស្នាលប្រកបដោយភាតរភាព អាស្រ័យហេតុនេះ អ្នកស្រាវជ្រាវសូមបញ្ជាក់អះអាងថាទិន្នន័យដែលលោកគ្រូអ្នកគ្រូបានបំពេញក្នុងកម្រងសំណួរជាគំនិតផ្ទាល់ខ្លួនរបស់ពួកគាត់ពិតប្រាកដ គឺមិនស្ថិតក្រោមឥទ្ធិពល ឬការបង្គាប់បញ្ជាពីអ្នកស្រាវជ្រាវដែលជានាយកសាលានោះឡើយ។

### ៣.៥- ការវិភាគទិន្នន័យ

ដោយសារការស្រាវជ្រាវប្រធានបទខាងលើនេះ ជាការស្រាវជ្រាវតាមបែបគុណវិស័យនោះ អ្នកស្រាវជ្រាវបានធ្វើការវិភាគទិន្នន័យ ដែលទទួលបានមកពីកម្រងសំណួរសម្ភាសតាមបែបគុណវិស័យ ដែរ។

ដោយឡែកសម្រាប់ការវិភាគតាមបែបគុណវិស័យវិញ អ្នកស្រាវជ្រាវបានផ្ដោតជាចម្បងលើផ្នែកទីបី និងទីបួន ដែលលើកឡើងពីបញ្ហាប្រឈមក្នុងការប្រើប្រាស់សៀវភៅសិក្សាគោលនានា និងទស្សនៈយល់ឃើញផ្សេងៗរបស់សំណាកពាក់ព័ន្ធនឹងការអនុវត្តសៀវភៅសិក្សាគោលភាសាអង់គ្លេសនៅទីនោះ។ ទិន្នន័យដែលបានមកពីសំណាកតាមរយៈកម្រងសំណួរសម្ភាសត្រូវបានប្រមូលផ្ដុំគំនិត ដោយទិន្នន័យណាដែលដូចគ្នាត្រូវដាក់ជាមួយគ្នាយកជាគំនិតរួមទៅតាមប្រភេទនៃ

ខ្លឹមសារ លំដាប់លំដោយខ្លឹមសារ និងទាញយកមកវិភាគទៅតាមផ្នែកនីមួយៗ ដើម្បីបង្ហាញឲ្យឃើញពីឫសគល់នៃបញ្ហាប្រឈម និងតម្រូវការជាក់ស្តែង ព្រមទាំងគំនិតយល់ឃើញចំពោះបញ្ហាប្រឈមក្នុងការអនុវត្តសៀវភៅសិក្សាគោលភាសាអង់គ្លេសនៅមធ្យមសិក្សាក្នុងវិស័យអប់រំ នៅក្នុងខេត្តតាកែវ។

# ជំពូក៤
# ទិដ្ឋភាពនានានៃវិទ្យាល័យក្នុងខេត្តតាកែវ

# ជំពូក៤
# ទិដ្ឋភាពនានានៃវិទ្យាល័យក្នុងខេត្តតាកែវ

## ៤.១- សាវតាខេត្តតាកែវ

តាកែវជាខេត្តមួយស្ថិតនៅចម្ងាយប្រមាណ៧៨គីឡូម៉ែត្រ និងមានទីតាំងនៅភាគខាងត្បូងរាជធានីភ្នំពេញ។ ជាទឹកដីភូមិសាស្ត្រតាំងពីបរមបុរាណធ្លាប់មានអរិយធម៌និងវប្បធម៌រុងរឿងគួរជាទីស្នេហាក្រៃលែង។ តឹកតាងប្រវត្តិសាស្ត្រទាំងនេះសបញ្ជាក់ថា អ្នករស់នៅលើទឹកដីនេះជាមនុស្សមានឆន្ទៈសតិសម្បជញ្ញៈនិងឧត្តមភាពខ្ពស់ប្រកបដោយការខិតខំតស៊ូប្រឹងប្រែងមិនធម្មតា។ មកដល់បច្ចុប្បន្ននេះខេត្តតាកែវក៏នៅតែបន្តរក្សានូវសក្តានុពលខ្លាំងរបស់ខ្លួនលើគ្រប់វិស័យ ដែលក្នុងនោះក៏មានវិស័យអប់រំគឺជាវិស័យអទិភាពចម្បងមួយផងដែរដែលកំពុងត្រូវការអភិវឌ្ឍន៍ និងកែលម្អឲ្យកាន់តែប្រសើរឡើងនូវកត្តាផ្សេងៗជាចាំបាច់។ ក្នុងនោះផងដែរ ខេត្តតាកែវមានក្រុងចំនួន ០១ និងស្រុកចំនួន ០៩ សង្កាត់ចំនួន ០៣ ឃុំចំនួន ៩៧ និងភូមិចំនួន ១១១៧ភូមិ ដែលបានបែងចែកដូចតទៅ: ក្រុងដូនកែវដែលមាន០៣សង្កាត់គឺ ១ សង្កាត់បារាយណ៍ ២ សង្កាត់រកាក្នុង ៣ សង្កាត់រកាក្រៅ។ ចំពោះស្រុក ទី១ ស្រុកអង្គរបុរី មានឃុំចំនួន ០៦ឃុំ ទី២ ស្រុកត្រាំងកក់ មានឃុំចំនួន ១៥ឃុំ ទី៣ ស្រុកសំរោងមានឃុំចំនួន១១ឃុំ ទី៤ ស្រុកបាទី មានឃុំចំនួន ១៥ឃុំ ទី៥ ស្រុកកោះអណ្តែត មានឃុំចំនួន ០៦ឃុំ ទី៦ ស្រុកគីរីវង់ មានឃុំចំនួន ១២ឃុំ ទី៧ ស្រុកបូរីជលសារ មានឃុំចំនួន ០៥ឃុំ ទី៨ ស្រុកទ្រាំង មានឃុំចំនួន ១៤ឃុំ ទី៩ ស្រុកព្រៃកប្បាស មានឃុំចំនួន ១៣ឃុំ។

## ៤.២-វិស័យអប់រំ

វិស័យអប់រំគឺជាវិស័យមួយដែលមានសារសំខាន់ ក្នុងការអភិវឌ្ឍធនធានមនុស្សឱ្យមានចំណេះដឹងសមត្ថភាពដែលធ្វើឱ្យមានការអភិវឌ្ឍនៅក្នុងសង្គម ធ្វើឱ្យប្រទេសមានការីកចម្រើន និងឈានទៅរកការប្រកួតប្រជែងជាមួយអន្តរជាតិ។ យ៉ាងណាមិញក្រឡេកមកមើលវិស័យអប់រំនៅក្នុងខេត្តតាកែវ វិញមានការរីកចម្រើនគួរសម ដែលយើងឃើញមានសាលារីកដុះដាលយ៉ាងច្រើនទាំងផ្នែក បឋមសិក្សា និងមធ្យមសិក្សា មិនថាអនុវិទ្យាល័យ ឬវិទ្យាល័យទេ វិស័យអប់រំត្រូវបានទទួលស្គាល់និងឱ្យតម្លៃទៅលើការការអប់រំជាខ្លាំង។ ជារួមនៅក្នុងខេត្តតាកែវ មានក្រុងចំនួនមួយ និងស្រុកចំនួនប្រាំបួន ដែលមានប្រជាជនរស់នៅច្រើន។ ចំពោះការអប់រំនិងទីកន្លែងអប់រំនៅតាមស្រុកនីមួយៗ ដែលមានវិទ្យាល័យទាំងអស់ចំនួន ៥៣ វិទ្យាល័យដែលបានបែងចែកទៅតាមស្រុកនីមួយៗ ដើម្បីជាកន្លែងសម្រាប់ការផ្តល់ចំណេះដឹងដល់អ្នកសិក្សា។

## ៤.៣- ស្ថិតិបុគ្គលិក និងចំនួនសិស្ស

ដោយបានដឹងហើយថា សាលានៅក្នុងខេត្តតាកែវមានចំនួនច្រើន ចំពោះបុគ្គលិកក៏មិនតិចដែរ ចំនួនបុគ្គលិកអប់រំនៅក្នុងខេត្តតាកែវ មានចំនួនសរុប ៣២៩០ នាក់ ក្នុងនោះស្រីមានចំនួន ៩៥៩នាក់ដែលបានកំពុងបម្រើការ នៅតាមសាលានានាក្នុងខេត្ត។ ចំពោះសិស្សដែលកំពុងសិក្សាក៏មានចំនួនច្រើនដូចគ្នា ចំនួនសិស្សសរុបមាន ៧៣៨៤៣ នាក់ ក្នុងនោះមានសិស្សស្រីចំនួន ៣៨៣៩៣នាក់ដែលបានកំពុងសិក្សានៅក្នុងខេត្តតាកែវ។

## ៤.៤- ទិដ្ឋភាពពីវិទ្យាល័យភ្នំមាស

### ៤.៤.១- ព័ត៌មានអំពីសាលា

បច្ចុប្បន្នវិទ្យាល័យភ្នំមាសស្ថិតនៅក្នុងឃុំព្រៃផ្ដៅ ស្រុកព្រៃកប្បាស ខេត្តតាកែវ។

ក្នុងឆ្នាំសិក្សា២០២១-២០២២ វិទ្យាល័យភ្នំមាសមានអាគារសិក្សាចំនួន ១១ អាគារ នឹងមានទីចាត់ការចំនួន១ខ្នង បណ្ណាល័យ១ខ្នង ។

ចំពោះបុគ្គលិកនៅក្នុងវិទ្យាល័យភ្នំមាសមានសរុបចំនួន ៩៥នាក់ ក្នុងនោះមានស្រីចំនួន១៩នាក់។ ក្នុងនោះបុគ្គលិកបម្រើការនៅមធ្យមសិក្សាទុតិយភូមិមានចំនួន ៥២នាក់ ស្រីចំនួន ១១នាក់ បុគ្គលិកបម្រើការនៅមធ្យមសិក្សាបឋមភូមិមានចំនួន ៤៣នាក់ ស្រីចំនួន ៨នាក់

ចំនួនសិស្សដែលបានកំពុងសិក្សានៅក្នុងឆ្នាំ២០២១-២០២២ នៅវិទ្យាល័យភ្នំមាសមានសិស្សសរុបចំនួន ១៩៥៣នាក់ ស្រីមានចំនួន ៩៨៧នាក់។ និងមានថ្នាក់សរុបចំនួន ៤៧ថ្នាក់ ដែលបានបែងចែកទៅតាមកម្រិតថ្នាក់ដូចខាងក្រោម៖

នៅក្នុងវិទ្យាល័យភ្នំមាសមាន ថ្នាក់ទី ១២ មានចំនួន ៨ ថ្នាក់ និងថ្នាក់ទី ១១ មានចំនួន ៨ ថ្នាក់ព្រមទាំងថ្នាក់ទី ១០ មានចំនួន ៨ ថ្នាក់ នេះអចំពោះទុតិយភូមិ ចំពោះនៅមធ្យមសិក្សាបឋមភូមិមានថ្នាក់ទី ៩ មានចំនួន ៨ ថ្នាក់ និងថ្នាក់ទី ៨ មានចំនួន ៧ ថ្នាក់ និងថ្នាក់ទី ៧ មានចំនួន ៨ ថ្នាក់។

## ៤.៤.២-ប្លង់វិទ្យាល័យភ្នីមាស




វិទ្យាល័យភ្នីមាសស្ថិតក្រោមការគ្រប់គ្រងរបស់លោក គឹម ហួត ដែលត្រូវជានាយកសាលា



## ៤.៤.៣- រូបភាពនានានៃវិទ្យាល័យ












## ៤.៥-ទិដ្ឋភាពនៃវិទ្យាល័យ ប៊ុន រ៉ានី ហ៊ុនសែន បាទី

### ៤.៥.១- ប្រវត្តិសង្ខេបវិទ្យាល័យ ប៊ុន រ៉ានី ហ៊ុនសែន បាទី

វិទ្យាល័យ ប៊ុនរ៉ានីហ៊ុនសែនបាទី ជាសាលាដែលមានប្រវត្តិចំណាស់ជាងគេក្នុងចំណោម វិទ្យាល័យ ទាំង៥ ក្នុងស្រុកដែលមានទីតាំងនៅក្នុង ភូមិត្រពាំងលាន ឃុំចំបក់ ស្រុកបាទី ខេត្តតាកែវ តាមបណ្តោយ ផ្លូវជាតិលេខ២ ដែលមានចម្ងាយប្រមាណ ១គីឡូម៉ែត្រខាងត្បូងសាលាស្រុកបាទី។

វិទ្យាល័យ ប៊ុនរ៉ានីហ៊ុនសែនបាទី បានកសាងឡើងនៅឆ្នាំ១៩៥៩ និងចាប់ដំណើរការរៀនសូត្រនៅ ឆ្នាំ១៩៦០ ដែលកាលនោះមានឈ្មោះថា អនុវិទ្យាល័យ ចំបក់ និងគ្រប់គ្រងដោយលោកនាយក អ៊ី សឿង និងលោកអគ្គានុរក្ស កាំង ហាក់អ៊ី។

នៅឆ្នាំសិក្សា ១៩៦៧-១៩៦៨ លោកនាយក អ៊ី សឿន និងលោក កាំង ហាក់អ៊ី បានផ្លាស់ចេញ ហើយ ជំនួសដោយ លោកនាយក សោម សែន និងលោកអគ្គានុរក្ស គៀ ភីស្វ៉ា ។

នៅឆ្នាំសិក្សា ១៩៦៩-១៩៧០ តាមសំណូមពររបស់សហគមន៍មាតាបីតាសិស្សអនុវិទ្យាល័យចំបក់ ត្រូវបានបង្កើតជា វិទ្យាល័យ ចំបក់ ដែលមានថ្នាក់ទី២ ទំនើបជាតិចំនួន២ថ្នាក់ ។ ប៉ុន្តែចាប់ពីថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ សាលាត្រូវបានបិទទ្វារដោយមូលហេតុសង្គ្រាមស៊ីវិល ។

នៅចន្លោះឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ អគារសិក្សាដែលនៅសេសសល់ពីសង្គ្រាមត្រូវ របប ប៉ុលពត យកធ្វើជា មន្ទីរពេទ្យស្រុក ៥៦។

ក្រោយថ្ងៃរំដោះ ៧ មករា ១៩៧៩ វិទ្យាល័យត្រូវបានបើកទ្វារដើម្បីទទួលសិស្សឱ្យបានចូលរៀនសារ ជាថ្មី ប៉ុន្តែប្តូរទីតាំងទៅនៅសាលាបឋមសិក្សា អង្គរុន ឃុំត្រពាំងក្រសាំង ស្រុកបាទី ខេត្តតាកែវ។

នៅឆ្នាំសិក្សា ១៩៨០-១៩៨១ សាលាបានផ្លាស់មកទីតាំងដើមវិញ ហើយមានឈ្មោះថា សាលាកម្រិតមធ្យមសិក្សាទី២ បាទី ដែលគ្រប់គ្រងដោយលោកនាយក ប្រាក់ ធុច និងនាយករង ឡឹក សាម៉ន។

នៅឆ្នាំសិក្សា ១៩៨២ ដល់ ១៩៨៤ សាលាកម្រិតមធ្យមសិក្សាទី២ បាទី គ្រប់គ្រងដោយលោក ឯក ឆោម និងនាយករង ឡឹក សាម៉ន។ ប៉ុន្តែនៅក្នុងឆ្នាំ១៩៨៤ លោកនាយករង ឡឹក សាម៉ន បានផ្លាស់ទៅ បម្រើការនៅការិយាល័យ អប់រំយុវជន និងកីឡា ស្រុកបាទី។

នៅឆ្នាំ ១៩៨៤ ដល់ ១៩៨៦ សាលាកម្រិតមធ្យមសិក្សាទី២ បាទី គ្រប់គ្រងដោយ លោក ឯក ឆោម និងនាយករង គឹប គឹមញ៉ាន។

នៅឆ្នាំសិក្សា ១៩៨៦-៨៧ សាលាកម្រិតមធ្យមសិក្សាទី២ បាទី ត្រូវបានប្តូរទៅជា សាលា

មធ្យមសិក្សា កម្រិត១-២ បាទី ដែលគ្រប់គ្រងដោយលោកនាយក ឯក ឆោម លោកនាយករង តឹប គឹមញ៉ាន លោក នាយករង យា សារឹម និងលោកនាយករង សួង ដួន ។

នៅឆ្នាំ ១៩៩០ សាលាកម្រិតមធ្យមសិក្សាទី២ បាទី បានប្តូរមកជា វិទ្យាល័យ បាទី ដែលគ្រប់គ្រង ដោយគណៈគ្រប់គ្រងខាងលើ។

នៅឆ្នាំ១៩៩៨ លោកនាយក យា សារឹម និងលោកនាយករង សួង ដួន បានចូលនិវត្តន៍។ គណៈគ្រប់គ្រងនៅសល់តែម្នាក់គត់គឺ លោក តឹប គឹមញ៉ាន ដែលទទួលភារកិច្ចជានាយកស្តីទី។

ក្នុងឆ្នាំសិក្សា ១៩៩៩-២០០០ សាលាបានរៀបចំគណៈគ្រប់គ្រងសារឡើងវិញ ដោយធ្វើសំណើរតែង តាំងលោក តឹប គឹមញ៉ាន ជានាយក។ បន្ទាប់មក នៅខែកុម្ភៈ ឆ្នាំ ២០០០ ក្រុមប្រឹក្សាវិន័យបានប្រជុំធ្វើសំណើរ តែងតាំង នាយករងចំនួន ៣រូប បន្ថែមទៀត គឺ លោក ប៉ក់ ពន្លកកែវ លោក យុគ សុង និងលោក ជួប ជុន។

ក្នុងឆ្នាំសិក្សា ២០០៧-២០០៨ ដោយអគារជួរខាងត្បូងមានវ័យចំណាស់មិនអាចសិក្សាបានក៏រុះរើ ចេញហើយសាងសង់វិញជាអគារមួយខ្នងពីរជាន់មាន១២បន្ទប់ជាជំនួយរបស់ សម្តេចអគ្គមហាសេនាបតី តេជោ ហ៊ុនសែន និងលោកជំទាវ ហើយស្របពេលនោះវិទ្យាល័យ បាទី បានប្តូរទៅជា វិទ្យាល័យ ប៊ុនរ៉ានីហ៊ុនសែនបាទី។

នៅក្នុងឆ្នាំ ២០១០ ដោយលោកនាយករង យុគ សុង បានប្តូរទៅ ការិយាល័យ អប់រំយុវជន និងកីឡា ស្រុកបាទី ហើយជ្រើសរើស លោក អ៊ួង ច័ន្ទស៊ីវុត្ថា ជំនួសវិញ។

នៅក្នុងឆ្នាំ២០១៤ លោក នាយករង ជួប ជុន ចូលនិវត្តិន៍ ហើយឆ្នាំ២០១៥ នាយក តឹប គឹមញ៉ាន ចូល និវត្តិន៍ និងឆ្នាំ២០១៦ លោក ប៉ក់ ពន្លកកែវ ចូលនិវត្តិន៍ដែរ ដូចនេះនៅសល់តែ លោក នាយករង អ៊ួង ច័ន្ទស៊ីវុត្ថា តែមួយគត់។

នៅថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៦ សម្តេច អគ្គមហាសេនាបតីតេជោ ហ៊ុនសែនបានផ្តល់អគារសិក្សា ១ខ្នង បីជាន់១៨បន្ទប់។ នៅថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០១៧ឯកឧត្តម ហ៊ុន ម៉ាណែត បានអញ្ជើញសួរសុខទុក្ខដល់លោកគ្រូ អ្នកគ្រូ និងសិក្សានុសិស្ស និងពិនិត្យមើលអគារសិក្សាដែលកំពុងសាងសង់ ជាអំណោយរបស់សម្តេច អគ្គមហាសេនាបតីតេជោ ហ៊ុនសែន និងសម្តេចកត្តិព្រឹតបណ្ឌិត ប៊ុនរ៉ានី ហ៊ុនសែន ហើយមិនតែប៉ុណ្ណោះ សម្តេចបានផ្តល់អគារសិក្សា ១ខ្នងបីជាន់ ៣០ បន្ទប់ និងទីចាត់ការ១ខ្នង ៣បន្ទប់ទៀត។

នៅក្នុងឆ្នាំ២០១៧ ក្រុមបឹក្សាវិន័យបានវាយតម្លៃលោកនាយករង អ៊ួង ច័ន្ទស៊ីវុត្ថា ទៅជានាយក និងលោក ហោ ប្រុស ជានាយករង។

នៅថ្ងៃទី០៤ ខែមិថុនាឆ្នាំ២០១៨ ក្រុមប្រឹក្សាវិន័យសាលាបានវាយតម្លៃលោក ហុង គំនិត

ដែលជាប្រធានក្រុម បច្ចេកទេសភូមិវិទ្យាជានាយករង។

នៅថ្ងៃទី០៣ខែធ្នូឆ្នាំ២០១៨ លោក ស៊ូ សែន ជានាយករង វិទ្យាល័យ ប៊ុនរ៉ានីហ៊ុនសែនស្លារមេ បានផ្លាស់មកធ្វើជានាយករងវិទ្យាល័យ ប៊ុនរ៉ានីហ៊ុនសែនបាទីវិញ។

## ៤.៥.២-ព័ត៌មានពីសាលា

នៅក្នុងឆ្នាំសិក្សា២០២១-២០២២ វិទ្យាល័យប៊ុន រ៉ានី ហ៊ុនសែនបាទីមានអាគារចំនួន ៨ ខ្នង និងមានបុគ្គលិកបម្រើការនៅក្នុងនោះចំនួន ១០៧នាក់ ក្នុងនោះស្រីមានចំនួន ៣៥នាក់។

+ ចំនួនគ្រូនៅផ្នែកមធ្យមសិក្សាទុតិយភូមិ មានចំនួន ៥៥នាក់ ក្នុងនោះស្រី ១៦នាក់

ចំនួនគ្រូមធ្យមសិក្សាបឋមភូមិ មានចំនួន ៥២នាក់ ក្នុងនោះស្រី ១៩នាក់។

នៅក្នុងឆ្នាំសិក្សា២០២១-២០២២ វិទ្យាល័យប៊ុន រ៉ានី ហ៊ុនសែនបាទី ដែលមានសិស្សកំពុងសិក្សាសរុបចំនួន ២១២៨ នាក់ ក្នុងនោះមានស្រីចំនួន ១០៩៦ នាក់។

មានអាគារចំនួន ៨ ខ្នង ដែលបានបែងចែកថ្នាក់សរុបចំនួន ៤៩ ថ្នាក់រៀនដូចតទៅៈ

នៅក្នុងវិទ្យាល័យ ប៊ុន រ៉ានី ហ៊ុនសេន បាទី មានថ្នាក់ទី ១២ មានចំនួន ០៨ ថ្នាក់ ចំណែកថ្នាក់ទី ១១ មានចំនួន ០៩ ថ្នាក់ និងថ្នាក់ទី១០ មានចំនួន ១០ថ្នាក់នៅក្នុងផ្នែកទុតិយភូមិ នៅក្នុងមធ្យមសិក្សាបឋមភូមិ មានថ្នាក់ទី ៩ មានចំនួន ០៦ ថ្នាក់ និងថ្នាក់ ៨ មានចំនួន ០៧ ថ្នាក់ ថ្នាក់ទី ៧ មានចំនួន ០៩ ថ្នាក់។

## ៤.៥.៣- ប្លង់វិទ្យាល័យ ប៊ុន រ៉ានី ហ៊ុនសែន បាទី





## ៤.៦- ទិដ្ឋភាពនៃវិទ្យាល័យសម្តេចឪ

### ៤.៦.១- ព័ត៌មានអំពីសាលា

វិទ្យាល័យសម្តេចឪ គឺជាវិទ្យាល័យដ៏ចំណាស់មួយដែលមានទីតាំងស្ថិតនៅក្នុងស្រុកសំរោង ខេត្តតាកែវ។

នៅឆ្នាំ២០២១-២០២២ វិទ្យាល័យសម្តេចឪ មានអាគារចំនួន ១០ខ្នង និងមានថ្នាក់រៀន ចំនួន ២៦ថ្នាក់។

វិទ្យាល័យសម្តេចឪ មានបុគ្គលិកសរុបចំនួន ៧០នាក់ ក្នុងនោះស្រី ១៧នាក់

បុគ្គលិកទុតិយភូមិ មានចំនួន ៤១ នាក់ ក្នុងនោះស្រី ១១ នាក់

បុគ្គលិកផ្នែកបមភូមិ មានចំនួន ៣៩ នាក់ ក្នុងនោះស្រី ៦ នាក់

ចំពោះសិស្សនៅក្នុងវិទ្យាល័យសម្តេចឪ មានសិស្សសរុបចំនួន ៩៤៥ នាក់ ក្នុងនោះស្រីមានចំនួន ៥០១ នាក់។

ចំពោះថ្នាក់រៀនមាន ២៦ថ្នាក់ដែលបានបែងចែកទៅតាមថ្នាក់ នៅមធ្យមសិក្សាទុតិយភូមិ មានថ្នាក់ទី ១២ មានចំនួន ០៤ ថ្នាក់ ទី ១១ មានចំនួន ០៥ ថ្នាក់ និងថ្នាក់ទី ១០ មានចំនួន ០៥ ថ្នាក់

ចំណែកនៅមធ្យមសិក្សាបឋមភូមិ មានថ្នាក់ទី ៩ មានចំនួន ០៤ ថ្នាក់ ទី ៨ មានចំនួន ០៤ ថ្នាក់ និងថ្នាក់ទី ៧ មានចំនួន ០៤ ថ្នាក់។

### ៤.៦.២- ខាងក្រោមនេះជាប្លង់វិទ្យាល័យសម្ដេចឪ



## ៤.៦.៣- រូបភាពនៃវិទ្យាល័យ











## ៤.៧- ទិដ្ឋភាពនៃវិទ្យាល័យហេងសំរិនព្រៃល្វា

## ៤.៧.១- ព័ត៌មានអំពីសាលា

បច្ចុប្បន្នវិទ្យាល័យ ហេងសំរិនព្រៃល្វា មានទីតាំងស្ថិតនៅទីរួមស្រុកព្រៃកប្បាស។

នៅក្នុងឆ្នាំសិក្សា២០២១-២០២២ វិទ្យាល័យហេងសំរិនព្រៃល្វាមានអាគារចំនួន ១១ខ្នង រួមទាំងទីចាត់ការ។

វិទ្យាល័យ ហេងសំរិនព្រៃល្វា មានបុគ្គលិកចំនួន ៦២ នាក់ ក្នុងនោះស្រីមានចំនួន ២០ នាក់។

ចំនួនចំនួនបុគ្គលិកផ្នែកបឋមភូមិ មានចំនួន ២៤ នាក់ ក្នុងនោះស្រីមាន ៨ នាក់

ចំនួនសិស្សនៅក្នុងវិទ្យាល័យហេងសំរិនព្រៃល្វា ក្នុងឆ្នាំសិក្សា ២០២១-២០២២ មានសិស្ស

សរុបចំនួន ១៩៦០ នាក់ ក្នុងនោះមានស្រីចំនួន ១០៣១ នាក់។

ចំពោះអាគារដែលមានចំនួន ១១ខ្នងនោះក៏បានបែងចែកថ្នាក់សម្រាប់សិក្សាផងដែរ ដែលមាន៖

នៅក្នុងវិទ្យាល័យហេងសំរិនព្រៃល្វា នៅក្នុងមធ្យមសិក្សាទុតិយភូមិ មានថ្នាក់ទី ១២ មានចំនួន ៨ ថ្នាក់ ទី ១១ មានចំនួន ៨ថ្នាក់ និងថ្នាក់ទី ១០ មានចំនួន ៨ ថ្នាក់ ចំពោះនៅក្នុងមធ្យមសិក្សាបឋមភូមិ មានថ្នាក់ទី ៩ មានចំនួន ៥ ថ្នាក់ ទី ៨ មានចំនួន ៥ ថ្នាក់ និងថ្នាក់ទី ៧ មានចំនួន ៥ ថ្នាក់

សរុបមកនៅឆ្នាំសិក្សា ២០២១-២០២២ វិទ្យាល័យហេងសំរិនព្រៃល្វា មានថ្នាក់សរុបចំនួន ៣៩ ថ្នាក់ ដែលមានថ្នាក់ទុតិយភូមិ ចំនួន ២៤ ថ្នាក់ និងថ្នក់បឋមភូមិ មានចំនួន ១៥ ថ្នាក់។

បុគ្គលិកផ្នែកទុតិយភូមិ មានចំនួន ៣៨ នាក់ ក្នុងនោះស្រីមាន ១២ នាក់



## ៤.៧.២- រូបភាពខ្លះនៃវិទ្យាល័យហេងសំរិនព្រៃល្វា









# ជំពូក៥
# លទ្ធផល និងការពិភាក្សា

# ជំពូក៥

# លទ្ធផល និងការពិភាក្សា

## ៥.១- ការសិក្សាពីបញ្ហាប្រឈមនៅក្នុងសៀវភៅគោលចាស់

នៅក្នុងចំណុចនៃការសិក្សាពីបញ្ហាការប្រើប្រាស់សៀវភៅសិក្សាគោលនេះ គឺអ្នកសិក្សានឹងសិក្សាស្រាវជ្រាវពីបញ្ហាប្រឈមនានាដែលកើតមានឡើងនៅក្នុងវិទ្យាល័យមួយចំនួនក្នុងខេត្តតាកែវ ជាពិសេសគឺសាលាគោលដៅតែម្តង។ ការសិក្សានោះគឺមានគោលបំណងដើម្បីនឹងបែងចែកការសិក្សាជាផ្នែកដូចជា៖ បញ្ហាប្រឈមទាក់ទងទៅនឹងសៀវភៅសិក្សាគោលចាស់(បញ្ហាប្រឈមនៃមេរៀន បញ្ហាប្រឈមនៃខ្លឹមសារមេរៀន និងបញ្ហាប្រឈមនៃវិធីសាស្រ្តបង្រៀន)។

### ៥.១.១-បញ្ហាប្រឈមនៃមេរៀន

ចំពោះបញ្ហាប្រឈមនៃមេរៀនគឺចង់និយាយយោងដល់រាល់បញ្ហានានារបស់មេរៀន ជាពិសេសលក្ខណៈមេរៀន ការរៀបចំមេរៀន ការរចនាមេរៀន និងទំហំនៃមេរៀនផងដែរ។ យោងទៅលើទិន្នន័យដែលទទួលបានពីការសម្ភាស យើងសង្កេតឃើញថា បញ្ហាប្រឈមនៃមេរៀនគឺបណ្តាលមកពីកត្តាជាច្រើនផងដែរ។ សូមបង្ហាញជូននៅតារាងនៃបញ្ហាប្រឈមខ្លះដូចខាងក្រោមនេះ។

**តារាងនៃបញ្ហាប្រឈមនៃមេរៀន**

| លេខរៀង | បញ្ហាប្រឈមនៃមេរៀននៅក្នុងសៀវភៅសិក្សាគោលចាស់ |
|---|---|
| ១ | មេរៀនមានលក្ខណៈវែងអន្លាយហួស |
| ២ | មេរៀនមិនសមាមាត្រទៅនឹងរបាយម៉ោងបង្រៀន |
| ៣ | មេរៀនមិនសូវបង្ហាញពីការអនុត្តជាក់ស្តែងជាពិសេសលើជំនាញទាំងបួន |
| ៤ | មេរៀនមិនលក្ខណៈគួរជាទីចាប់អារម្មណ៍របស់សិស្សានុសិស្ស |

ដូច្នេះ យើងយោងទៅលើការបង្ហាញតារាងនៃបញ្ហាប្រឈមខាងលើ យើងអាចធ្វើសេចក្តីសន្និដ្ឋានបានថា មេរៀននៅក្នុងសៀវភៅសិក្សាគោលចាស់គឺជាពិតជាមានបញ្ហាប្រឈមនិងនាំឱ្យមានបញ្ហាច្រើនដល់អ្នកដែលជាអ្នកផ្តល់សេវាអប់រំផង និងអ្នកទទួលបានសេវាអប់រំផងដែរ។

### ៥.១.២- បញ្ហាប្រឈមនៃខ្លឹមសារមេរៀន

ចំពោះបញ្ហាប្រឈមនៃខ្លឹមសារមេរៀនគឺសំដៅទៅដល់បញ្ហាទាំងឡាយរបស់ខ្លឹមសារមេរៀន ដែលអត្ថន័យនៃមេរៀនមានលក្ខណៈស៊ីជម្រៅ សកម្មភាពនៃមេរៀន បញ្ហាប្រឈមនៃខ្លឹមសារមេរៀន គឺបណ្តាលមកពីកត្តាមួយចំនួនដែលធ្វើឱ្យខ្លឹមសារមេរៀនមានបញ្ហា។ អ្នកសិក្សាសូមបង្ហាញជូនជាតារាងនៃបញ្ហាប្រឈមខ្លះនៃខ្លឹមសារមេរៀនដូចខាងក្រោមនេះ។

**តារាងនៃបញ្ហាប្រឈមខ្លឹមសាមេរៀន**

| លេខរៀង | បញ្ហាប្រឈមនៃខ្លឹមសារមេរៀននៅក្នុងសៀវភៅសិក្សាគោលចាស់ |
| --- | --- |
| ១ | ខ្លឹមសារមិនមានភាពទាក់ទាញ |
| ២ | កម្រិតសៀវភៅខ្ពស់ជាងកម្រិតយល់ដឹងរបស់សិស្ស |
| ៣ | ខ្លឹមសារមេរៀនមិនច្បាស់លាស់ |

ដូចនេះ ដោយផ្អែកទៅលើតារាងនៃបញ្ហាប្រឈមលើខ្លឹមសារមេរៀនដែលបានបង្ហាញជូនខាងលើ យើងអាចធ្វើសេចក្ដីសន្និដ្ឋានបានថា ខ្លឹមសារមេរៀននៅក្នុងសៀវភៅសិក្សាគោលចាស់ពិតជាមានបញ្ហាប្រឈម ព្រមទាំងនាំឱ្យមានបញ្ហាច្រើនទៅដល់អ្នកផ្ដល់សេវាអប់រំ និងអ្នកទទួលសេវាអប់រំផងដែរ។

### ៥.១.៣- បញ្ហាប្រឈមលើវិធីសាស្ត្រនៃការរៀបចំមេរៀន

នៅក្នុងបញ្ហាប្រឈមលើវិធីសាស្ត្រនៃការរៀបចំមេរៀន គឺចង់និយាយដល់រាល់បញ្ហានានាក្នុងការរៀបចំរៀននៅក្នុងសៀវ ជាពិសេសការរៀបចំមេរៀន សកម្មភាព ខ្លឹមសារមេរៀន ការបង្ហាញមេរៀនផងដែរ។ ដោយយោងទៅលើទិន្នន័យដែលទទួលបានតាមរយៈការធ្វើសម្ភាសមក យើងសង្កេតឃើញថា បញ្ហាប្រឈមលើវិធីសាស្ត្រនៃការរៀបចំមេរៀនគឺបណ្ដាលមកពីកត្តាជាច្រើន។ សូមបង្ហាញជូននៅតារាងអំពីបញ្ហាប្រឈមលើវិធីសាស្ត្រនៃការរៀបចំមេរៀនដូចខាងក្រោម៖

**តារាងបញ្ហាប្រឈមលើវិធីសាស្ត្រនៃការរៀបចំមេរៀន**

| លេខរៀង | បញ្ហាប្រឈមលើវិធីសាស្ត្រនៃការរៀបចំមេរៀននៅក្នុងសៀវភៅចាស់ |
| --- | --- |
| ១ | សកម្មភាពមេរៀនមិនមានភាពច្បាស់លាស់ |
| ២ | ខ្លឹមសារមេរៀនមិនបានបង្ហាញច្បាស់ |
| ៣ | សកម្មភាពមិនទស្សទាក់ទងទៅនិងជំនាញនៅក្នុងមេរៀន |
| ៤ | មេរៀននីមួយៗមានលក្ខណៈវែងច្រើនចំណុច។ |

ដូចនេះ បើយោងទៅលើតារាងដែលបានបង្ហាញពីបញ្ហាប្រឈមខាងលើ យើងអាចធ្វើការសន្និដ្ឋានបានថា វិធីសាស្ត្រនៃការរៀបចំមេរៀននៅក្នុងសៀវភៅចាស់ពិតជានាំឱ្យមានបញ្ហាប្រឈមដល់អ្នកអនុវត្តសៀវភៅ និងអ្នកដែលទទួលបានសេវាអប់រំអំពីសៀវភៅនេះផងដែរ។

### ៥.១.៤- បញ្ហាប្រឈមទាក់ទងនិងសម្ភារឧបទេស

នៅក្នុងចំណុចនៃការសិក្សាទៅលើបញ្ហាប្រឈមទាក់ទងនិងសម្ភារឧបទេសគឺចង់សំដៅរាល់បញ្ហានានាក្នុងការប្រើប្រាស់សម្ភារឧបទេសនៅក្នុងមេរៀននីមួយៗ ការផលិតសម្ភារ ភាពខ្វះខាតសៀវភៅសិក្សា វីដេអូជាដើម។ យោងទៅលើទិន្នន័យដែលបានមកពីការសម្ភាស យើងអាចសង្កេតឃើញថា បញ្ហាប្រឈមទាក់ទងនិងសម្ភារឧបទេសគឺមកពីកត្តាផ្សេងៗជាច្រើន។ សូមបង្ហាញជូនតារាងនៃបញ្ហាប្រឈមដែលទាក់ទងនិងសម្ភារឧបទេសដូចខាងក្រោម។

**តារាងនៃបញ្ហាប្រឈមកដែលទាក់ទងនិងសម្ភារឧបទេស**

| លេខរៀង | បញ្ហាប្រឈមទាក់ទងនិងសម្ភារឧបទេសនៅក្នុងសៀវភៅចាស់ |
|---|---|
| ១ | ពិបាកក្នុងការបង្កើតសម្ភារឱ្យស្របទៅនិងមេរៀន |
| ២ | ខ្វះសៀវភៅសិក្សាគោលសម្រាប់សិក្សា |
| ៣ | ពិបាកក្នុងការស្វែងរកវីដេអូ |
| ៤ | សម្លេងនៅក្នុងអត្ថបទស្តាប់ពិបាករក |

ដូច្នេះហើយ បើយោងទៅលើតារាងដែលបានបង្ហាញពីបញ្ហាប្រឈមទាក់ទងនិងសម្ភារឧបទេសខាងលើ អ្នកសិក្សាអាចសន្និដ្ឋានបានថា ការប្រើប្រាស់សម្ភារឧបទេសនៃមេរៀនក្នុងសៀវភៅចាស់ពិតជាមានបញ្ហាប្រឈមដល់អ្នកដែលផ្តល់សេវាអប់រំ ព្រមទាំងអ្នកទទួលសេវាអប់រំផងដែរ។

### ៥.១.៥- បញ្ហាប្រឈមនៃវិធីសាស្ត្របង្រៀន

នៅក្នុងការសិក្សាលើបញ្ហាប្រឈមនៃវិធីសាស្ត្របង្រៀនគឺចង់និយាយពីបញ្ហាផ្សេងៗលើវិធីសាស្ត្រដែលមាន ការបង្រៀន រៀបចំសកម្មភាព ជាដើម។ ដោយយោងទៅតាមទិន្នន័យដែលទទួលបានមកពីការសម្ភាស យើងអាចទាញសេចក្តីសន្និដ្ឋានបានថា បញ្ហាប្រឈមនៃវិធីសាស្ត្របង្រៀនពិតជាមានបញ្ហាប្រឈមពិតមែនដែលនាំឱ្យមានបញ្ហាដល់អ្នកអនុវត្តផងដែរ។ ទាំងនេះសូមបង្ហាញជូនតារាងនៃបញ្ហាប្រឈមវិធីសាស្ត្របង្រៀនដូចខាងក្រោម។

តារាងបញ្ហាប្រឈមលើវិធីសាស្ត្របង្រៀន

| លេខរៀង | បញ្ហាប្រឈមលើវិធីសាស្ត្របង្រៀននៅក្នុងសៀវភៅចាស់ |
|---|---|
| ១ | ខ្វះសម្ភារឧបទេស |
| ២ | ខ្វះសៀវភៅសិក្សាគោល |
| ៣ | ចំណេះដឹងរបស់សិស្ស |
| ៤ | វិធីសាស្ត្របង្រៀន |

ដូចនេះ បើយោងតាមការបង្ហាញតារាងបញ្ហាប្រឈមលើវិធីសាស្ត្របង្រៀន យើងអាចធ្វើសេចក្តីសន្និដ្ឋានបានថា វិធីសាស្ត្របង្រៀនពិតជាមានបញ្ហាប្រឈមចំពោះអ្នកអនុវត្តសៀវភៅ និងអ្នកទទួលការអប់រំផងដែរ។

### ៥.១.៦- សេចក្តីសន្និដ្ឋាន

បន្ទាប់ពីការបង្ហាញទៅលើតារាងបញ្ហាប្រឈមជាច្រើនចំណុចដូចជា បញ្ហាប្រឈមមេរៀន បញ្ហាប្រឈមខ្លឹមសារមេរៀន បញ្ហាប្រឈមលើវិធីសាស្ត្ររៀបចំមេរៀន បញ្ហាប្រឈមទាក់ទងនិងសម្ភារឧបទេស និងបញ្ហាប្រឈមលើវិធីសាស្ត្របង្រៀនខាងលើដែលមាននៅក្នុងសៀវភៅសិក្សាគោលចាស់មក យើងអាចធ្វើការសន្និដ្ឋានបានថា ពិតជាមានបញ្ហាប្រឈមជាច្រើនចំណុចចំពោះអ្នកអនុវត្តសៀវភៅ និងអ្នកទទួលការអប់រំពិតប្រាកដមែន ដែលធ្វើឱ្យគ្រូអាចឈានទៅដល់ការប្រើប្រាស់សៀវភៅសិក្សាគោលថ្មីវិញ។

## ៥.២. ការសិក្សាពីបញ្ហាប្រឈមនៅក្នុងសៀវភៅសិក្សាថ្មី

នៅក្នុងចំណុចនៃការសិក្សាពីបញ្ហាការប្រើប្រាស់សៀវភៅសិក្សាគោលនេះ គឺអ្នកសិក្សានឹងសិក្សាស្រាវជ្រាវពីបញ្ហាប្រឈមនានាដែលកើតមានឡើងនៅក្នុងវិទ្យាល័យមួយចំនួនក្នុងខេត្តតាកែវ ជាពិសេសគឺសាលាគោលដៅតែម្តង។ ការសិក្សានោះគឺមានគោលបំណងដើម្បីនឹងបែងចែកការសិក្សាជាផ្នែកដូចជា៖ បញ្ហាប្រឈមសៀវភៅសិក្សាគោលថ្មី (បញ្ហាប្រឈមនៃមេរៀន បញ្ហាប្រឈមនៃខ្លឹមសារមេរៀន និងបញ្ហាប្រឈមនៃវិធីសាស្ត្របង្រៀន)។ លើសពីនេះ យើងក៏បង្ហាញការសិក្សាប្រៀបធៀបរវាងសៀវភៅសិក្សាគោលទាំងពីរផងដែរ។ សូមបង្ហាញជូនការសិក្សាដូចខាងក្រោមនេះ។

### ៥.២.១- បញ្ហាប្រឈមនៃមេរៀន

នៅក្នុងការសិក្សាលើបញ្ហាប្រឈមនៃមរៀននៅក្នុងសៀវភៅថ្មីនេះចង់និយាយតែលើបញ្ហានានាដែលទាក់ទងនិងមេរៀនដែលជា លក្ខណៈមេរៀន ការរចនាមេរៀន ទំហំមេរៀន ការរៀបចំមេរៀនជាដើម។ ដោយយោងទៅលើទិន្នន័យដែលទទួលបានមកពីការធ្វើសម្ភាសរបស់លោកគ្រូ អ្នកគ្រូមក ឃើញបញ្ហាប្រឈមនៃមេរៀនបណ្តាលមកពីកត្តាមួយចំនួន។ អ្នកសិក្សាសូមបង្ហាញនៅតារាងពីបញ្ហាប្រឈមមេរៀននៅក្នុងសៀវភៅសិក្សាគោលថ្មីដូចខាងក្រោម។

**តារាងបញ្ហាប្រឈមនៃមេរៀននៅក្នុងសៀវភៅសិក្សាគោលថ្មី**

| លេខរៀង | បញ្ហាប្រឈមនៃមេរៀននៅក្នុងសៀវភៅសិក្សាគោលថ្មី |
|---|---|
| ១ | មេរៀនវែងអន្លាយ ច្រើនចំណុច |
| ២ | មិនសូវមានរូបភាព |
| ៣ | ខ្លឹមសារមេរៀននិងសកម្មភាពមិនសូវទាក់ទងគ្នា |
| ៤ | គោលបំណងមេរៀនមិនសូវច្បាស់លាស់ |

ដូចនេះបើយោងទៅលើការបង្ហាញអំពីតារាងនៃបញ្ហាប្រឈមមេរៀននៅក្នុងសៀវភៅសិក្សាគោលថ្មី អ្នកសិក្សាអាចធ្វើការសន្និដ្ឋានបានថាគឺពិតជានាំឱ្យមានបញ្ហាច្រើនដល់អ្នកផ្តល់សេវាអប់រំនិងអ្នកទទួលសេវាអប់រំផងដែរ។

### ៥.២.២- បញ្ហាប្រឈមនៃខ្លឹមសារមេរៀន

នៅក្នុងការសិក្សាលើបញ្ហាប្រឈមនៃខ្លឹមសារមេរៀន គឺចង់សំដៅដល់បញ្ហានានាដែលទាក់ទងទៅនិងខ្លឹមសារនៃមេរៀនដែលមានខ

**តារាងបញ្ហាប្រឈមនៃខ្លឹមសារមេរៀននៅក្នុងសៀវភៅសិក្សាថ្មី**

| លេខរៀង | បញ្ហាប្រឈមនៃខ្លឹមសារមេរៀន |
|---|---|
| ១ | មេរៀនមិនសូវមានរូបភាពទាក់ទងនិងខ្លឹមសារ |
| ២ | ខ្លឹមសារមេរៀនវែងច្រើនចំណុច |
| ៣ | ខ្លឹមសារមេរៀន និងជំនាញមិនសូវទាក់ទងគ្នា |
| ៤ | មិនសូវមានសកម្មភាពអនុវត្តមេរៀន |

ដូចនេះបើយោងទៅលើបញ្ហាប្រឈមនៃខ្លឹមសារមេរៀនដែលបានបង្ហាញជូនខាងលើ យើងអាចសន្និដ្ឋានបានថា បញ្ហាប្រឈមខ្លឹមសារមេរៀនគឺបណ្ដាលមកពីកត្តាជាច្រើន ដែលបណ្ដាលឱ្យមានបញ្ហាទៅដល់អ្នកប្រើប្រាស់សៀវភៅ ព្រមទាំងអ្នកទទួលការអប់រំពីសៀវភៅ។

### ៥.២.៣- បញ្ហាប្រឈមនៃវិធីសាស្ត្ររៀបចំមេរៀន

នៅក្នុងករណីបញ្ហាប្រឈមនៃវិធីសាស្ត្ររៀបចំមេរៀននៅក្នុងសៀវភៅសិក្សាគោលថ្មីនេះ គឺចង់លើកយកពីបញ្ហានៃការ រៀបចំមេរៀន ការបង្ហាញនៃខ្លឹមសារ រៀបចំសកម្មភាព និងលក្ខណៈនៃមេរៀនផងដែរ។ យោងទៅលើទិន្នន័យដែលបានមកតាមរយៈនៃការធ្វើសម្ភាស ឃើញថាបញ្ហាប្រឈមលើវិធីសស្ត្ររៀបចំមេរៀន គឺបណ្ដាលមកពីកត្តមួយចំនួន។ដើម្បីបានដឹងថាបញ្ហាប្រឈមមានអ្វីខ្លះ សូមបង្ហាញជូនតារាងបញ្ហាប្រឈមដូចខាងក្រោម។

**តារាងបញ្ហាប្រឈមនៃវិធីសាស្ត្ររៀបចំមេរៀន**

| លេខរៀង | បញ្ហាប្រឈមនៃវិធីសាស្ត្ររៀបចំមេរៀន |
|---|---|
| ១ | មេរៀនមានលក្ខណៈវែងអន្លាយ |
| ២ | មិនសូវមានសកម្មភាព |
| ៣ | ខ្លឹមសារមេរៀននិងជំនាញមិនសូវទាក់ទងគ្នា |
| ៤ | មេរៀនមិនសូវមានរូបភាព |
| ៥ | កម្រិតមេរៀនខ្ពស់ជាងកម្រិតសិស្ស |

ដូចនេះតាមរយនៃការបង្ហាញតារាងបញ្ហាប្រឈមនៃវិធីសាស្ត្ររៀបចំមេរៀននៅក្នុងសៀវភៅសិក្សាគោលថ្មីមក យើងអាចសន្និដ្ឋានបានថា ការរៀបចំសៀវភៅពិតជាមានបញ្ហាប្រឈមជាច្រើន ដែលជាកត្តានាំឱ្យ មានបញ្ហាប្រឈមដល់អ្នកផ្ដល់សេវាអប់រំ ព្រមទាំងអ្នកដែលទទួលសេវាអប់រំផងដែរ។

### ៥.២.៤- បញ្ហាប្រឈមទាក់ទងនិងសម្ភារបង្រៀន

នៅក្នុងការសិក្សាពីបញ្ហាប្រឈមទាក់ទងនិងសម្ភារបង្រៀន គឺចង់និយាយសំដៅដល់រាល់បញ្ហានានាក្នុងការប្រើប្រាស់សម្ភារនៅក្នុងសៀវភៅសិក្សាគោលថ្មី ប្រសិនបើយោងទៅលើទិន្នន័យបញ្ហាប្រឈមនៃការផលិតនិងប្រើប្រាស់សម្ភារឧបទេសនៅក្នុងសៀវភៅសិក្សាគោលថ្មី។ សូមបង្ហាញជូននៅតារាងបញ្ហាប្រឈមទាក់ទងសម្ភារឧបទេសដូចតខាងក្រោម។

### តារាងបញ្ហាប្រឈមទាក់ទងនិងសម្ភារឧបទេសនៅក្នុងសៀវភៅសិក្សាថ្មី

| លេខរៀង | បញ្ហាប្រឈមទាក់ទងនិងសម្ភារឧបទេស |
|---|---|
| ១ | ខ្វះសៀវភៅសិក្សាគោល |
| ២ | ពិបាកក្នុងការបង្កើតសម្ភារទាក់ទងនិងសកម្មភាពមេរៀន |
| ៣ | ខ្វះខាតសម្ភារសម្រាប់វីដេអូ និងសម្លេង |

ដូចនេះ ដោយផ្អែកទៅលើការបង្ហាញតារាងនៃបញ្ហាប្រឈមដែលទាក់ទងនិងសម្ភារឧបទេសនៅក្នុងសៀវភៅថ្មី យើងអាចធ្វើការសន្និដ្ឋានបានថា ការបង្កើតសម្ភារ និងការប្រើប្រាស់សម្ភារ គឺបណ្ដាលមកពីកត្តាមួយចំនួន ដែលពិតជាធ្វើឱ្យមានបញ្ហាប្រឈមនិងនាំឱ្យមានបញ្ហាច្រើនដល់អ្នកអនុវត្តសៀវភៅ និងអ្នកទទួលសេវាអប់រំនៅក្នុងសៀវភៅនោះផងដែរ។

## ៥.២.៥- បញ្ហាប្រឈមនៃវិធីសាស្ត្របង្រៀន

ការសិក្សានៅក្នុងចំណុចនេះ អ្នកសិក្សានិងវិភាគទៅលើបញ្ហាផ្សេងៗនៅក្នុងការប្រើប្រាស់ទៅលើវិធីសាស្ត្របង្រៀននៅក្នុងសៀវភៅសិក្សាគោលថ្មី ដោយយោងទៅលើទិន្ន័យដែលទទួលបានតាមរយៈការធ្វើសម្ភាស ឃើញថាការប្រើប្រាស់លើវិធីសាស្ត្របង្រៀនផ្សេងៗគ្នា លើការបង្រៀនរៀបចំមេរៀន សម្ភារបង្រៀន ក៏ដូចជាការបង្រៀន វិធីសាស្ត្រសិស្សមជ្ឈមណ្ឌល គ្រូមជ្ឈមណ្ឌល និងតាមបែបចម្រុះជាដើម ដោយយោងទៅលើទិន្នន័យដែលបានមក យើងឃើញថាពិតជាមានបញ្ហាច្រើនទៅដល់អ្នកផ្ដល់សេវា និងអ្នកទទួលសេវាអប់រំដូចគ្នា។ ដោយយោងទៅលើទិន្នន័យ អ្នកសិក្សាសូមបង្ហាញតារាងនៃបញ្ហាប្រឈមលើវិធីសាស្ត្របង្រៀនដូចខាងក្រោម។

### តារាងនៃបញ្ហាប្រឈមលើវិធីសាស្ត្របង្រៀន

| លេខរៀង | បញ្ហាប្រឈមនៃវិធីសាស្ត្របង្រៀននៅក្នុងសៀវភៅថ្មី |
|---|---|
| ១ | ខ្វះសម្ភារបង្រៀន |
| ២ | ខ្វះសៀវភៅសិក្សាគោល |
| ៣ | ចំណេះដឹងរបស់សិស្ស |
| ៤ | វិធីសាស្ត្រនិងខ្លឹមសារមេរៀន |

តាមរយៈនៃការបង្ហាញតារាងបញ្ហាប្រឈមលើវិធីសាស្ត្របង្រៀនខាងលើយើងអាចសន្និដ្ឋានបានថាពិតជាមានបញ្ហាប្រឈមច្រើន យោងតាមទិន្ន័យខាងលើយើងអាចសន្និដ្ឋានបានថាបញ្ហា

ប្រឈមនៃវិធីសាស្ត្របង្រៀនពិតជាបណ្តាលមកពីកត្តាជាច្រើន និងមានបញ្ហាប្រឈមចំពោះ អ្នកអនុវត្តសៀវភៅ និងអ្នកទទួលសេវាអប់រំ។

### ៥.៣- បញ្ហាប្រឈមផ្សេងៗ

នៅក្នុងចំណុចនេះ អ្នកសិក្សានឹងសិក្សាវិភាគទៅលើបញ្ហាប្រឈមផ្សេងៗ នៅក្នុងការអនុវត្តសៀវភៅគោលសិក្សាថ្មី យោងតាមទិន្នន័យដែលទទួលបានពីការសម្ភាស ដែលបានការទាក់ទងទៅនិងកត្តាមួយចំនួន ។ សូមបង្ហាញជូនពីការសិក្សាដូចខាងក្រោម។

#### ៥.៣.១- ការទាក់ទងសៀវភៅសិក្សាគោល

នៅក្នុងចំណុចនេះ អ្នកសិក្សាចង់និយាយពីបញ្ហាប្រឈមនានាដែលមានការពាក់ព័ន្ធជាមួយសៀវភៅសិក្សាគោលចាស់ និងសៀវភៅសិក្សាគោលថ្មី យោងតាមទិន្នន័យដែលទទួលបានពីការសម្ភាស ឃើញថាមានកត្តាជាច្រើន។ សូមបង្ហាញជូនតារាងបញ្ហាប្រឈមទាក់ទងសៀវភៅចាស់ និងសៀវភៅថ្មី។

**តារាងបង្ហាញបញ្ហាប្រឈមទាក់ទងសៀវភៅសិក្សាគោល**

| បញ្ហាប្រឈមសៀវភៅចាស់ | បញ្ហាប្រឈមសៀវភៅថ្មី |
|---|---|
| សៀវភៅមិនបានធ្វើបច្ចុប្បន្នភាព | ការចែញផ្សាយសៀវភៅសិក្សាគោលយឺត |
| ខ្លឹមសារមេរៀនចាស់មិនឆ្លើយតបសកម្មភាព | ខ្វះសៀវភៅសិក្សាគោល |
| មេរៀន និងខ្លឹមសារ | មេរៀន និងខ្លឹមសារ |
| វិធីសាស្ត្រក្នុងការរៀបចំមេរៀន | |

ដូច្នេះ យើងយោងទៅតាមការបង្ហាញតារាងនៃបញ្ហាប្រឈមនិងសៀវភៅសិក្សាគោលទាំងពីរ យើងអាចធ្វើសេចក្តីសន្និដ្ឋានបានថា បញ្ហាប្រឈមលើសៀវភៅសិក្សាគោល ពិតជាមានកត្តាជាច្រើនដែលធ្វើឱ្យអ្នកប្រើប្រាស់មានបញ្ហាប្រឈមដូចគ្នា។

#### ៥.៣.២- សមត្ថភាពគ្រូ

នៅក្នុងការសិក្សាចំណុចនេះ អ្នកសិក្សាចង់និយាយ ពីបញ្ហាប្រឈមនានាទៅលើសមត្ថភាពគ្រូនៅក្នុងការអនុវត្ត យោងទៅលើទិន្នន័យដែលទទួលបានតាមរយៈសម្ភាស យើងអាចធ្វើសេចក្តីសន្និដ្ឋានបានទៅលើការបង្រៀន ការរៀបចំមេរៀន ឯកសារជាដើម។ សូមបង្ហាញនៅតារាងដែលជាបញ្ហាប្រឈមលើសមត្ថភាពរបស់គ្រូ។

**តារាងបញ្ហាប្រឈមនៃសមត្ថភាពគ្រូ**

| លេខរៀង | បញ្ហាប្រឈមសមត្ថភាពគ្រូ |
|---|---|
| ១ | ឯកសារបង្រៀនមានស្រាប់ |
| ២ | វិធីសាស្ត្របង្រៀន |
| ៣ | ការបង្កើតសម្ភារឧបទេស |

ដូចដែលបានបង្ហាញតារាងបញ្ហាប្រឈមខាងលើ យោងតាមទិន្នន័យខាងលើ យើងអាចសន្និដ្ឋានថា បញ្ហាប្រឈមសមត្ថភាពគ្រូនៅក្នុងការអនុវត្តសៀវភៅ ពិតជាមានបញ្ហាប្រឈមក្នុងការអនុវត្តសៀវភៅទាំងអ្នកផ្តល់ និងអ្នកទទួលសេវាអប់រំផងដែរ។

## ៥.៤- ការប្រៀបធៀបបញ្ហាប្រឈមរវាងសៀវភៅចាស់ និងសៀវភៅថ្មី និងកត្តាផ្សេងៗ

### ៥.៤.១- បញ្ហាប្រឈមមានលក្ខណៈដូចគ្នារវាងសៀវភៅចាស់ សៀវភៅថ្មី និងកត្តាផ្សេងៗ

នៅក្នុងការសិក្សាទៅលើបញ្ហាប្រឈមដែលមានលក្ខណៈដូចគ្នា អ្នកសិក្សាចង់សំដៅទៅដល់បញ្ហាប្រឈមនានានៅក្នុងសៀវភៅចាស់ និងសៀវភៅថ្មី ដោយយោងទៅលើទិន្នន័យដែលបានបង្ហាញខាងលើ យើងអាចប្រៀបធៀបលក្ខណៈដូចៗ សូមបង្ហាញជូនតារាងដែលមានបញ្ហាប្រឈមដូចគ្នានៅក្នុងសៀវភៅចាស់ និងសៀវភៅថ្មី។

**តារាងបញ្ហាប្រឈមដូចគ្នានៅក្នុងសៀវភៅចាស់ និងសៀវភៅថ្មី និងកត្តាផ្សេងៗ**

| លេខរៀង | បញ្ហាប្រឈមដូចគ្នានៅក្នុងសៀវភៅចាស់ និងថ្មី និងកត្តាផ្សេងៗ |
|---|---|
| ១ | មេរៀនមានលក្ខណៈវែងអន្លាយ ច្រើនចំណុច |
| ២ | ពិបាកក្នុងការបង្កើតសម្ភារ |
| ៣ | ខ្វះសៀវភៅសិក្សាគោល |
| ៤ | ចំណេះដឹងសិស្ស |
| ៥ | វិធីសាស្ត្ររៀបចំមេរៀន |
| ៦ | សកម្មភាពនិងខ្លឹមសារមិនសូវទាក់ទងនិងជំនាញទាំងបួន |
| ៧ | ខ្វះសម្ភារឧបទេស |
| ៨ | កម្រិតសៀវភៅខ្ពស់ជាងចំណេះដឹងសិស្ស |
| ៩ | មេរៀនមិនសូវមានភាពទាក់ទាញ |

ដោយផ្អែកទៅលើការបង្ហាញតារាងបញ្ហាប្រឈមនីមួយៗមក យោងទៅលើទិន្នន័យនេះ យើងអាចធ្វើសេចក្តីសន្និដ្ឋានបានថា បញ្ហាប្រឈមរវាងសៀវភៅសិក្សាគោលចាស់ និងសៀវភៅសិក្សាគោលថ្មី មានបញ្ហាប្រឈមដូចគ្នាជាច្រើនចំណុច យោងទៅតាមទិន្ន័យដែលបានបង្ហាញនៅក្នុងតារាងខាងលើនេះ។

### ៥.៤.២- បញ្ហាប្រឈមមានលក្ខណៈខុសគ្នានៅក្នុងសៀវភៅចាស់ និងសៀវភៅថ្មី និងកត្តផ្សេងៗ

នៅក្នុងការសិក្សាលើបញ្ហាប្រឈមមានលក្ខណៈខុសគ្នានៅក្នុងសៀវភៅចាស់ និសៀវភៅថ្មី អ្នកសិក្សាគ្រាន់តែចង់និយាយលើបញ្ហាប្រឈមនានាដែលមានលក្ខណៈខុសគ្នា ដោយយោងទៅលើទិន្នន័យដែលបានបង្ហាញនៅក្នុងតារាបញ្ហាប្រឈមខាងលើមក ទើបយើងអាចធ្វើសេចក្តីសន្និដ្ឋានថាបញ្ហាប្រឈមរឿងសៀវភៅចាស់ និងថ្មីមានបញ្ហាប្រឈមមានលក្ខណៈខុសគ្នាខ្លះផងដែរ។ សូមបង្ហាញជូនតារាងបញ្ហាប្រឈមមានលក្ខណៈខុសគ្នាដូខខាងក្រោម។

**តារាងបញ្ហាប្រឈមមានលក្ខណៈខុសគ្នានៅក្នុងសៀវភៅចាស់ និងសៀវភៅថ្មី**

| លេខរៀង | បញ្ហាប្រឈមខុសគ្នានៅក្នុងសៀវភៅចាស់ និងថ្មីកត្តាផ្សេងៗ |
|---|---|
| ១ | មិនសមាមាត្រនិងរបាយម៉ោង |
| ២ | មេរៀនមិនសូវមានរូបភាព |
| ៣ | វិធីសាស្ត្រសរសេរនិងរៀបចំមេរៀន |
| ៤ | ការបង្ហាញខ្លឹមសារមេរៀន |
| ៥ | ខ្លឹមសារមេរៀននៅក្នុងសៀវភៅ |
| ៦ | ការចេញផ្សាយសៀវភៅសិក្សាយឺត |

ដោយយោងទៅលើការបង្ហាញពីតារាងបញ្ហាប្រឈមនីមួយៗរួចមក តាមទិន្នន័យដែលបានមក ធ្វើឱ្យអ្នកសិក្សាអាចធ្វើសេចក្តីសន្និដ្ឋានបានថាបញ្ហាប្រឈមនៅក្នុងសៀវភៅសិក្សាគោលចាស់ និង ថ្មីគឺមានកត្តាមួយចំនួនដែលមានលក្ខណៈខុសគ្នា និងជាបញ្ហាដែលបណ្តាលឱ្យអ្នកអនុវត្តសៀវភៅបានប្រើប្រាស់សៀវភៅខុសគ្នា។

## ៥.៥- សេចក្តីសន្និដ្ឋាន

សរុបសេចក្តីមកក្នុងការប្រើប្រាស់សៀវភៅសិក្សាគោលចាស់ក្តី និងសៀវភៅសិក្សាគោលថ្មីក្តី សុទ្ធតែមានបញ្ហាប្រឈមទៅលើអ្នកផ្តល់សេវាអប់រំ និងអ្នកទទួលសេវាអប់រំដូចគ្នា។ តាមទិន្នន័យ

ដែលបានធ្វើការបង្ហាញទៅលើតារាងនៃបញ្ហាប្រឈមនានានៅក្នុងការប្រើប្រាស់សៀវភៅសិក្សាគោលចាស់ និងសៀវភៅសិក្សាគោលថ្មីរួចមកសបញ្ជាក់ឱ្យឃើញថា មិនថាជាការអនុវត្តសៀវភៅសិក្សាគោលចាស់ ឬការអនុវត្តសៀវភៅសិក្សាគោលថ្មីនោះទេ គឺសៀវភៅនីមួយៗសុទ្ធតែមានចំណុចនៃបញ្ហាប្រឈមមួយចំនួនដូចគ្នា និងមានបញ្ហាប្រឈមមួយចំនួនមិនដូចគ្នា។ យោងទៅលើការបង្ហាញទិន្នន័យនេះទើបធ្វើឱ្យយើងអាចសន្និដ្ឋានបានថា ដោយមានបញ្ហាប្រឈមនៅក្នុងសៀវភៅចាស់ដូចជាបញ្ហាប្រឈមទៅលើ មេរៀន ខ្លឹមសារមេរៀន សម្ភារឧបទេស កម្រិតសៀវភៅខ្ពស់ជាងចំណេះដឹងរបស់សិស្ស សកម្មភាពនៅក្នុងមេរៀនជាដើម។ ដោយឃើញមានបញ្ហាប្រឈមផ្សេងៗជាច្រើនទៅលើសៀវភៅសិក្សាគោលចាស់បែបនេះទើបធ្វើឱ្យអ្នកអនុវត្តសៀវភៅមួយចំនួនឈនដល់ការប្តូរពីអនុវត្តសៀវភៅសិក្សាគោលចាស់ ទៅអនុវត្តសៀវភៅសិក្សាគោលថ្មីវិញ។ ដូចគ្នានេះដែរបើយោងទៅលើការអនុវត្តសៀវភៅសិក្សាគោលថ្មីវិញយើងឃើញថាមានបញ្ហាប្រឈមជាច្រើនផងដែរ ដូចជា ការចេញផ្សាយសៀវភៅសិក្សាគោលយឺត មេរៀនមានលក្ខណៈវែង សម្ភារឧបទេស ការរៀបចំមេរៀន សកម្មភាព សមត្ថភាពគ្រូ ជាដើម ។ ដោយឃើញថាការអនុវត្តសៀវភៅសិក្សាគោលថ្មីមានបញ្ហាប្រឈមបែបនេះទើបធ្វើឱ្យអ្នកអនុវត្តសៀវភៅសិក្សាគោលចាស់មិនចង់មានការផ្លាស់ប្តូរទៅលើការអនុវត្តសៀវភៅសិក្សាគោលថ្មីឡើយ បែបនេះហើយទើបមានការអនុវត្តសៀវភៅសិក្សាគោលចាស់ផង និងសៀវភៅសិក្សាគោលថ្មីផង។

# ជំពូក៦

# សេចក្តីសន្និដ្ឋាន  អនុសាសន៍ និងសំណូមពរ

# ជំពូក៦
# សេចក្តីសន្និដ្ឋាន អនុសាសន៍ និងសំណូមពរ

## ៦.១- សេចក្តីសន្និដ្ឋាន

ដោយបានធ្វើការសិក្សា ព្រមទាំងបានឆ្លងកាត់តាមរយៈការវិភាគ និងតាមរយៈការពិភាក្សាបកស្រាយទៅលើលទ្ធផលដែលបានធ្វើការស្រាវជ្រាវខាងលើនេះ យើងអាចធ្វើសេចក្តីសន្និដ្ឋានបានថា បញ្ហាប្រឈមក្នុងការប្រើប្រាស់សៀវភៅសិក្សាគោលភាសាអង់គ្លេសនៅមធ្យមសិក្សាក្នុងខេត្តតាកែវ ឃើញថាលោកគ្រូ អ្នកគ្រូភាគច្រើនមានបញ្ហាប្រឈមមួយចំនួនដែលមានការបង្កឱ្យមានភាពរាំងស្ទះដល់ការអនុវត្តសៀវភៅ ទន្ទឹមនិងការស្រាវជ្រាវនៅបញ្ហាខ្លះៗខាងលើតាមការបង្ហាញទិន្នន័យដែលបានមកនេះ អាចធ្វើឱ្យអ្នកសិក្សារកឃើញនៅចំណុចមួយចំនួនដែលជាបញ្ហាប្រឈមដល់ការអនុវត្តសៀវភៅសិក្សាគោលចាស់ ដែលយោងទៅលើទិន្នន័យដែលបានបង្ហាញឃើញថាមានបញ្ហាប្រឈមលើការខ្វះសៀវភៅសិក្សាគោលសម្រាប់សិស្សក្នុងការរៀនសូត្រ បញ្ហាប្រឈមទៅលើខ្លឹមសារមេរៀន សកម្មភាពនៅក្នុងមេរៀន ការរៀបចំមេរៀន ខ្វះសម្ភារឧបទេស ខ្លឹមសារមេរៀនមិនឆ្លើយតបទៅនិងជំនាញទាំងបួន វិធីសាស្ត្រក្នុងការបង្រៀនជាដើម។ ទាំងអស់នេះហើយដែលជាបញ្ហាប្រឈមក្នុងការអនុវត្តសៀវភៅសិក្សាគោលចាស់ដែលធ្វើឱ្យលោកគ្រូ អ្នកគ្រូ ព្រមទាំងសិស្សមានការលំបាកក្នុងដំណើរការបង្រៀន និងរៀន ព្រមទាំងធ្វើឱ្យអ្នកអនុវត្តមានការឈានទៅអនុវត្តសៀវភៅសិក្សាគោលថ្មីវិញ។

ចំពោះការស្រាវជ្រាវនេះផងដែរ តាមការបង្ហាញតារាងបញ្ហាប្រឈមនៅក្នុងការអនុវត្តសៀវភៅសិក្សាគោលថ្មី ដោយយោងដែលទទួលបានមក ធ្វើឱ្យអ្នកសិក្សារកឃើញនៅចំណុចដែលជាបញ្ហាប្រឈមដល់ការអនុវត្តសៀវភៅសិក្សាគោលថ្មី តាមរយៈទិន្នន័យនេះ យើងអាចឃើញមានបញ្ហាប្រឈមដូចជា ការខ្វះសម្ភារឧបទ្ទេស ខ្វះសៀវភៅសិក្សាគោលសម្រាប់សិក្សា ការផ្សព្វផ្សាយសៀវភៅគោលសិក្សាយឺតយ៉ាវ មេរៀនមិនសូវមានរូបភាព ឯកសារបង្រៀន សមត្ថភាពបង្រៀនរបស់គ្រូ មេរៀនវែងច្រើនចំណុចជាដើម។ ហើយកត្តាទាំងនេះហើយដែលជាបញ្ហាប្រឈមក្នុងការអនុវត្តសៀវភៅសិក្សាគោលថ្មីនេះ និងជាកត្តាដែលបណ្តាលឱ្យអ្នកអុនវត្តសៀវភៅពុំមានការចង់ផ្លាស់ប្តូរពីការអនុវត្តសៀវភៅគោលសិក្សាចាស់ ទៅអនុវត្តសៀវភៅគោលសិក្សាថ្មីឡើយ។

សរុបជារួមមកបន្ទាប់ពីធ្វើការបកស្រាយលើប្រធានបទខាងលើជាច្រើនមក យើងឃើញថាបញ្ហាប្រឈមក្នុងការប្រើប្រាស់សៀវភៅសិក្សាគោលភាសាអង់គ្លេសនៅមធ្យមសិក្សាក្នុងខេត្តតាកែវពិតជាមានបញ្ហាប្រឈមក្នុងការអនុវត្តសៀវភៅសិក្សាគោលនៅតាមសាលានានាមែន មិនថាជាការអនុវត្តសៀវភៅសិក្សាគោលចាស់ ឬសៀវភៅសិក្សាគោលថ្មីឡើយ ដោយយោងទៅលើការបក

ស្រាយបញ្ហាប្រឈមនេះ ទើបធ្វើឱ្យអ្នកអនុវត្តសៀវភៅសិក្សាគោលចាស់ផង និងអនុវត្តលើសៀវភៅសិក្សាគោលថ្មីផង។

## ៦.២- ការផ្តល់អនុសាសន៍

ដោយឆ្លងទៅតាមការបកស្រាយយ៉ាងក្បោះក្បាយទៅលើប្រធានបទខាងលើដែលបង្ហាញពីលទ្ធផលដែលអាចបញ្ជាក់ឱ្យឃើញថា បញ្ហាប្រឈមមានច្រើនទៅលើការអនុវត្តសៀវភៅសិក្សាគោលចាស់ផង សៀវភៅសិក្សាគោលថ្មីផងដែលធ្វើឱ្យមានបញ្ហាប្រឈមច្រើន ដូចនេះសូមសំណូមពរ នៅក្នុងសាលាមួយ សូមកុំឱ្យមានការអនុវត្តសៀវភៅពីរផ្សេងគ្នាដូចនេះ សូមឱ្យមានការអនុវត្តតែសៀវភៅមួយដើម្បីធ្វើឱ្យការអនុវត្តសៀវភៅសិក្សាគោលមានគោលដៅតែមួយ។

## ៦.៣- សំណូមពរ

ក្រោយពីបានធ្វើការបកស្រាយវែកញែក និងស្រាវជ្រាវទៅលើបញ្ហាប្រឈមខាងលើរួចមក និងបានដឹងនៅបញ្ហាប្រឈមមួយចំនួននោះ យើងឃើញថា បញ្ហាប្រឈមខ្លាំងជាងគេគឺទាក់ទងទៅនិងសៀវភៅសិក្សាគោល ហេតុនេះហើយសូមសំណូមពរទៅដល់ ក្រសួងអប់រំ និងនាយកដ្ឋានជំនាញ ព្រមទាំងស្ថាប័នដែលពាក់ព័ន្ធសូមជួយផ្តល់សៀវភៅសិក្សាគោលតែមួយប្រភេទ ទៅដល់សាលាសម្រាប់ធ្វើការអនុវត្ត និងផ្តល់សេវាអប់រំក្នុងទិសដៅតែមួយ។ ហើយមួយទៀតនោះសៀវភៅសិក្សាគោលសូមឱ្យមានការកាត់មន្ថយនូវចំនួនមេរៀន ដោយកាត់ចោលនៅចំណុចដែលមិនបានទាក់ទងនិងមេរៀន។ សៀវភៅសិក្សាគោលទៀតសោតសុំឱ្យមានមេរៀនសមស្របទៅនិងកម្រិតព្រមទាំងមានចំណេះដឹងរបស់សិស្ស។ សូមកែសម្រួលទៅលើខ្លឹមសារមេរៀននៅក្នុងសៀវភៅទាក់ទងទៅនិងសកម្មភាពជាក់ស្តែងនៅក្នុងសង្គម សកម្មភាពនៃមេរៀនសូមឱ្យមានការទាក់ទងទៅនិងជំនាញនីមួយៗដើម្បីមានភាពច្បាស់លាស់ដល់ការអនុវត្តរបស់លោកគ្រូ

សូមសំណូមពរទៅដល់មន្ទីរអប់រំ ព្រមទាំងគណៈគ្រប់គ្រងសាលានានា សូមមានការអនុវត្តទៅលើសៀវភៅសិក្សាគោលបានសិក្សាគ្រប់ៗគ្នានៅក្នុងគោលដៅតែមួយ។

ហើយខ្ញុំសង្ឃឹមថា និងមានអ្នកសិក្សាស្រាវជ្រាវជំនាន់ក្រោយៗ និងខិតខំសិក្សាស្រាវជ្រាវបន្ថែមទៀតដើម្បីស្វែងរកនូវបញ្ហាប្រឈមផ្សេងៗទៀតដែលមានភាពកាន់តែមានសារៈសំខាន់ជាងនេះទៅទៀត ហេតុនេះសូមអ្នកសិក្សាស្រាវជ្រាវក្រោយៗដែលមានបំណងចង់សិក្សាបន្តទៅលើប្រធានបទនេះ អ្នកស្រាវជ្រាវក្រោយៗគួរតែមានការពង្រឹងទៅលើវិសាលភាពចំណេះដឹងរបស់ខ្លួនព្រមទាំងដែនកំណត់ឱ្យបានទូលំទូលាយជាងនេះបន្ថែមទៀតប្រសិនបើចង់សិក្សាទៅលើប្រធានបទនេះបន្តទៀត។

# ឯកសារយោង


ក្រសួង អប់រំ យុវជន  និងកីឡា ( ២០១៥) *កំណែទម្រង់វិស័យអប់រំ* ភ្នំពេញ។

ក្រសួង អប់រំ យុវជន និងកីឡា ( ២០១៥)*កែប្រែកម្មវិធីសៀវភៅសិក្សាគោល* ភ្នំពេញ។

ក្រសួងអប់រំ យុវជន និងកីឡា ( ២០០៨) *សាលាមធ្យមសិក្សាធនធាន* ភ្នំពេញ ។

ក្រសួងអប់រំ យុវជន និងកីឡា (២០០៤) *គោលនយោបាយសម្រាប់អភិវឌ្ឍន៍កម្មវិធីសិក្សាចំណេះទូទៅ* ភ្នំពេញ។

ក្រសួងអប់រំ យុវជន និងកីឡា ( ២០១៦) *ក្របខណ្ឌកម្មវិធីសិក្សាចំណេះទូទៅ និងអប់រំបច្ចេកទេស* ភ្នំពេញ។

ក្រសួងអប់រំ យុវជន និងកីឡា (២០១៨) *កម្មវិធីសិក្សាលម្អិត ភាសាអ់គ្លេសកម្រិតមធ្យមសិក្សាទុតិយភូមិ* ភ្នំពេញ។

ក្រសួងអប់រំ យុវជន និងកីឡា (២០០៨)*ប្រកាសស្តីពីការដាក់ឱ្យប្រើប្រាស់កម្មវិធីសិក្សាលម្អិតគ្រប់មុខវិជ្ជានៅកម្រិតមធ្យមសិក្សាទុតិយភូមិ* ភ្នំពេញ។

ក្រសួងអប់រំ យុវជន និងកីឡា (២០០៨)*ប្រកាសស្តីពីការដាក់ឱ្យប្រើប្រាស់កម្មវិធីសិក្សាលម្អិតគ្រប់មុខវិជ្ជានៅកម្រិតមធ្យមសិក្សាបឋមភូមិ* ភ្នំពេញ។

ក្រសួងអប់រំ យុវជន និងកីឡា ( ២០០៨) *ប្រកាសស្តីពីការដាក់ឱ្យប្រើប្រាស់កម្មវិធីសិក្សាគ្រប់មុខវិជ្ជានៅកម្រិតបឋម* ភ្នំពេញ។

ក្រសួងអប់រំ យុវជន និងកីឡា (២០១២) *កម្មវិធីសិក្សាលម្អិតភាសាអង់គ្លេសសម្រាប់មធ្យមសិក្សាបឋមភូមិ ទី ៧* ភ្នំពេញ។

ក្រសួងអបើរំ យុវជន និងកីឡា (២០១២) *កម្មវិធីសិក្សាលម្អិតភាសាអង់គ្លេសសម្រាប់មធ្យមសិក្សាបឋមភូមិ ៨* ភ្នំពេញ។

ក្រសួងអបើរំ យុវជន និងកីឡា (២០១២) *កម្មវិធីសិក្សាលម្អិតភាសាអង់គ្លេសសម្រាប់មធ្យមសិក្សាបឋមភូមិ ៩* ភ្នំពេញ។

ក្រសួងអប់រំ យុវជន និងកីឡា ( ២០១១) *ការអភិវឌ្ឍយុវជនកម្ពុជា* ភ្នំពេញ។

ក្រសួងអប់រំ យុវជន និងកីឡា ( ២០១៨) *ក្របខណ្ឌគន្លងអាជីពគ្រូបង្រៀន* ភ្នំពេញ។

ក្រសួងអប់រំ យុវជន និងកីឡា ( ២០១៦) *កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការក្នុងវិស័យអប់រំ* ភ្នំពេញ។

ក្រសួងអប់រំ យុវជន និងកីឡា ( ២០១៣) *គោលនយោបាយស្តីពីគ្រូបង្រៀន* ភ្នំពេញ។

ក្រសួងអប់រំ យុវជន និងកីឡា ( ២០១៣) *គោលនយោបាយស្តីពីការអប់រំបច្ចេកទេស* ភ្នំពេញ។

ក្រសួងអប់រំ យុវជន និងកីឡា ( ២០១២) *គោលនយោបាយស្តីពី ធនធានមនុស្ស ក្នុងវិស័យអប់រំ* ភ្នំពេញ។
ក្រសួងអប់រំ យុវជន និងកីឡា (២០១២)*គោលនយោបាយស្តីពីសៀវភៅសិក្សា និងមគ្គុទេសក៏សម្រាប់ការអភិវឌ្ឍសៀវភៅសិក្សាគោល* ភ្នំពេញ។
ក្រសួងអប់រំយុវជន និងកីឡា ( ២០១៦) *ការអភិវឌ្ឍធនធានមនុស្ស* ភ្នំពេញ។
ក្រសួងអប់រំយុជន និងកីឡា (២០១៥) *យុទ្ធសាស្រ្តវិស័យអប់រំឆ្នាំ២០១៥* ភ្នំពេញ។
ក្រសួងអប់រំ យុវជន និងកីឡា (២០១៤) *ក្របខ័ណ្ឌគុណវុឌ្ឍិជាតិកម្ពុជា* ភ្នំពេញ។
ក្រសួងអប់រំ យុវជន និងកីឡា (២០២២) *ការគ្រប់គ្រងបុគ្គលិកនៅតាមសាលារៀន* ភ្នំពេញ។
ក្រសួងអប់រំ យុវជន និងកីឡា ( ២០០០)*គោលការណ៍ណែនាំអនុវត្តយុទ្ធសាស្រ្តសហគមន៍សាលារៀនសម្រាប់អនុវិស័យអប់រំកុមារតូច* ភ្នំពេញ។
ក្រសួងអប់រំ យុវជន និងកីឡា (២០២១-២០៣០)*យុសាស្រ្តអនុវិស័យការអប់រំមធ្យមសិក្សា* ភ្នំពេញ។
ក្រសួងអប់រំ យុវជន និងកីឡា(២០១២) *គោលនយោបាយស្តីពីសៀវភៅសិក្សា* ភ្នំពេញ។
ក្រសួងអប់រំ យុវជន និងកីឡា (២០០៧) *ច្បាប់ស្តីពីការអប់រំ* ភ្នំពេញ។
ក្រសួងអប់រំ យុវជន និងកីឡា (២០១៤-២០១៨) *ផែនការយុទ្ធសាស្រ្តវិស័យអប់រំ* ភ្នំពេញ។
ក្រសួងអប់រំ យុវជន និងកីឡា (២០១៨) *កម្មវិធីសិក្សាលម្អិតភាសាអង់គ្លេសកម្រិតមធ្យមសិក្សាទុតិយភូមិ* ភ្នំពេញ។
ក្រសួងអប់រំ យុវជន និងកីឡា (ឆ្នាំ២០១៦)*ក្របខណ្ឌលម្អិតកម្មវិធីសិក្សាចំណេះទូទៅ និងអប់រំបច្ចេកទេស* ភ្នំពេញ។
ក្រសួងអប់រំ យុវជន និងកីឡា (២០១២) *កម្មវិធីសិក្សាលម្អិតភាសាអង់គ្លេសសម្រាប់បឋមសិក្សាថ្នាក់ទី ៤* ភ្នំពេញ។
ក្រសួងអប់រំ យុវជន និងកីឡា (២០១២) *កម្មវិធីសិក្សាលម្អិតភាសាអង់គ្លេសសម្រាប់បឋមសិក្សាថ្នាក់ទី៥* ភ្នំពេញ។
ក្រសួងអប់រំ យុវជន និងកីឡា (២០១២) *កម្មវិធីសិក្សាលម្អិតភាសាអង់គ្លេសសម្រាប់បឋមសិក្សាថ្នាក់ទី៦* ភ្នំពេញ។
ក្រសួងអប់រំ យុវជន និងកីឡា(២០១២)*សៀវភៅសិក្សាគោលភាសាអង់គ្លេសសម្រាប់អនុវិទ្យាល័យ ថ្នាក់ទី៧ ទី៨ ទី៩* ភ្នំពេញ។

ក្រសួងអប់រំ យុវជន និងកីឡា ( ២០០៥-២០០៩) *គោលនយោបាយសម្រាប់អភិវឌ្ឍន៍កម្មវិធី ចំណេះទូទៅ* ភ្នំពេញ។
គរុនិស្សិតជំនាន់ទី ២៦ ( ២០២២) *វិធីសាស្រ្តបង្រៀនសញ្ញាកត់សូរអន្តរជាតិនៅកម្រិតមធ្យម សិក្សាទុតិយភូមិ* ភ្នំពេញ។
ចៅ ឧស្សាហ៍ (២០១៨) *អធិការអប់រំ បរិញ្ញាបត្រជាន់ខ្ពស់គ្រប់គ្រងអប់រំ* ភ្នំបេញ។
បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុង (២០២១) *ការអនុវត្តវិធីសាស្រ្តបង្រៀនថ្មីដើម្បីកែលម្អលទ្ធផល សិក្សាសិស្ស* ភ្នំពេញ។
បណ្ឌិត ម៉ក់ បេន (២០១៣) *វចនានុក្រម អង់គ្លេស-ខ្មែរ* ភ្នំពេញ។
បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន ( ២០២០)*កំណែទម្រង់សាលារៀននៅកម្ពុជា* ភ្នំពេញ។
បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន (២០២១) *ទស្សនវិទ្យានិងទ្រឹស្តី ស្តីពីការអប់រំ* ភ្នំពេញ។
បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន (២០១៦)*កំណែទម្រង់វិស័យអប់រំនៅកម្ពុជា* ភ្នំពេញ។
លោក ទូត វាសនា (២០១៤-២០១៦)*ការប្រើប្រាស់សៀវភៅសិក្សាគោលនៅមធ្យមសិក្សា* ភ្នំពេញ។
លោក ថៃ ណាត្រី (២០១៨-២០២០) *ការប្រើប្រាស់សៀវភៅសិក្សាគោលភាសាអង់គ្លេស* ភ្នំពេញ។
លោក សៀង គីមឈឿន (២០១៧-២០១៩)*ការអនុវត្តសៀវភៅសិក្សាគោល* ភ្នំពេញ។

វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា (២០១៤) *ការពង្រឹងគុណភាពអប់រំ* ភ្នំពេញ។
វិទ្យាស្ថានជាតិអប់រំ (២០២០)*ក្របខ័ណ្ឌកម្មវិធីសិក្សា* ភ្នំពេញ។
សម្តេចសង្ឃរាជ ជួន ណាត (១៩៦៧ ) *វចនានុក្រមខ្មែរ* ភ្នំពេញ។
Asean Economic Community (AEC) ( 2015).
English Dictionary (2011). *Oxford English Dictionary.*
Ministry of Education, Youth and Sport (2000) *English For Cambidia Book six text book.*
Ministry of Education, Youth and Sport (2012) *Policy of Human Resource in Education Sector.*
Ministry of Education, Youth and Sport (2013) *Teacher Policy.*

The Ministry of Education, Youth and Sports (2008) *Secondary Resource Schools Policy*.

# ឧបសម្ព័ន្ធ

# ព្រះរាជាណាចក្រកម្ពុជា

# ជាតិ  សាសនា ព្រះមហាក្សត្រ

# កម្រងសំណួរស្រាវជ្រាវ

ខ្ញុំបាទឈ្មោះ ទុយ សុខា ជានិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី ៩ នៃវិទ្យាស្ថានជាតិអប់រំ (ហៅកាត់ជាភាសាអង់គ្លេសថា NIE) បានរៀបចំធ្វើការស្រាវជ្រាវអំពី"បញ្ហាប្រឈមក្នុងការប្រើប្រាស់សៀវភៅសិក្សាគោលភាសាអង់គ្លេសនៅមធ្យមសិក្សាក្នុងខេត្តតាកែវ"។ ខ្ញុំមបាទសូមរំខាន លោកគ្រូ អ្នកគ្រូមេត្តាជួយឆ្លើយសំណួរទាំងអស់ខាងក្រោមនេះ ។ ខ្ញុំបាទជឿជាក់ថាការឆ្លើយរបស់លោកគ្រូ អ្នកគ្រូពិតជាមានសារៈសំខាន់សម្រាប់ការស្រាវជ្រាវមួយនេះ។ ដូច្នេះសូមលោកគ្រូ អ្នកគ្រូមេត្តាឆ្លើយដោយក្ដីអនុគ្រោះ និងយោគយល់ប្រសិនបើលោកគ្រូ អ្នកគ្រូចង់ដឹងព័ត៌មានបន្ថែម អំពីការសិក្សាមួយនេះ សូមសួរខ្ញុំបាទនឹងឆ្លើយជូនដោយក្ដីរីករាយ។

១- ព័ត៌មានអ្នកសម្ភាសន៍

ឈ្មោះ……………………ភេទ…………អាយុ…………..សញ្ជាតិ………………ការងារ………………..

ថ្ងៃខែឆ្នាំកំណើត………………………..ទីកន្លែងកំណើត………………………………………………..

លេខទូរស័ព្ទ……………………………………………………….។

២- សំណួរគោលដៅក្នុងការសម្ភាសន៍

ក-តើសៀវភៅសិក្សាគោលភាសាអង់គ្លេសដែលលោកគ្រូអ្នកគ្រូបង្រៀនបោះពុម្ពឆ្នាំ…… ………
…………………..មានមេរៀនចំនួន………………………………..?

ខ- តើមេរៀននៅក្នុងសៀវភៅឆ្លើយតបទៅនិងរបាយម៉ោងបង្រៀនដែរឬទេ?

…………………………………………………………………………………………………………

…………………………………………………………………………………………………………...។

គ- តើការអនុវត្តសៀវភៅសិក្សាគោលភាសាអង់គ្លេសរបស់លោកគ្រូ អ្នកគ្រូមានជួបបញ្ហាប្រឈមអ្វីខ្លះ?

……………………………………………………………………………………………….

……………………………………………………………………………………………….

……………………………………………………………………………………………….

……………………………………………………………………………………………….

……………………………………………………………………………………………….

……………………………………………………………………………………………….

ឃ- សូមលោកគ្រូ អ្នកគ្រូជួយបង្ហាញពីដំណោះស្រាយប្រសិនបើមានបញ្ហាប្រឈម។

……………………………………………………………………………………………….

……………………………………………………………………………………………….

……………………………………………………………………………………………….

……………………………………………………………………………………………….

……………………………………………………………………………………………….

……………………………………………………………………………………………….

……………………………………………………………………………………………….

……………………………………………………………………………………………….។

សូមលោកគ្រូ អ្នកគ្រូមេត្តាជួយផ្តល់អនុសាសន៍ចំពោះសៀវភៅសិក្សាគោលភាសាអង់គ្លេសនៅមធ្យមសិក្សានេះ និងសុំណួមពររបស់លោកគ្រូ អ្នកគ្រូ។

……………………………………………………………………………………………….

……………………………………………………………………………………………….

……………………………………………………………………………………………….

……………………………………………………………………………………………….

……………………………………………………………………………………………….

……………………………………………………………………………………………….

……………………………………………………………………………………………….

……………………………………………………………………………………………….

……………………………………………………………………………………………….

……………………………………………………………………………………………….។

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងអប់រំ យុវជន និងកីឡា
លេខ: ៦៧៤១ អយក.វក

ថ្ងៃ [illegible] ខែ [illegible] ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី[illegible] ខែ [illegible] ឆ្នាំ២០២២

**ជម្រាបជូន**
**លោក លោកស្រីប្រធានមន្ទីរអប់រំ យុវជន និងកីឡា រាជធានី ខេត្ត**

**កម្មវត្ថុ៖** ការចុះប្រមូលទិន្នន័យ ដើម្បីសរសេរនិក្ខេបបទបញ្ចប់ការសិក្សារបស់និស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៩។

**យោង៖** - បទប្បញ្ញត្តិស្តីពីការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ នៅវិទ្យាស្ថានជាតិអប់រំ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨។
- ផែនការអនុវត្តកម្មវិធីបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៩និងទី១០ ឆ្នាំសិក្សា២០២១-២០២២ ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០២១។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាប លោក លោកស្រីប្រធាន ជ្រាបថា៖ និស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៩ ចំនួន៥៨នាក់ នឹងចុះប្រមូលទិន្នន័យនៅតាមរាជធានីខេត្តនានា ដើម្បីសរសេរនិក្ខេបបទស្រាវជ្រាវបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ នៅវិទ្យាស្ថានជាតិអប់រំ ពីថ្ងៃទី០២ ខែឧសភា ឆ្នាំ២០២២ រហូតដល់ថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០២២។

អាស្រ័យហេតុនេះ សូម លោក លោកស្រីប្រធាន ជួយសម្រួល និងសហការដល់ការចុះប្រមូលទិន្នន័យខាងលើឱ្យមានប្រសិទ្ធភាពខ្ពស់។

សូម លោក លោកស្រីប្រធាន ទទួលនូវការរាប់អានដ៏ស្មោះពីខ្ញុំ។

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន

**ចម្លងជូន៖**
- អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ
- ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី "ដើម្បីជូនជ្រាបជាព័ត៌មាន"
- អង្គភាពក្រោមឱវាទក្រសួងអយក "ដើម្បីជ្រាបជាព័ត៌មាន"
- សាមីជន "ដើម្បីអនុវត្ត"
- កាលប្បវត្តិ
- ឯកសារ វិទ្យាស្ថានជាតិអប់រំ

# ឈ្មោះលោកគ្រូ អ្នកគ្រូដែលបានចូលរួមផ្តល់ទិន្នន

| លេខរៀង | ឈ្មោះលោកគ្រូអ្នកគ្រូ | ភេទ | លេខទូរស័ព្ទ | ផ្សេងៗ |
|---|---|---|---|---|
| ១ | ជា តត | ប្រុស | ០១៦ ៨៨១១៩២ | |
| ២ | សុខ សុភិរុណ | ប្រុស | ០៦១ ៥០៥០២៦ | |
| ៣ | នួន កែវ | ប្រុស | ០៨៧ ៩០២០០៣ | |
| ៤ | គួន សុខុម | ស្រី | ០១៧ ៩៧៩០៦៨ | |
| ៥ | សុខ តុលា | ប្រុស | ០៩៨ ៣៩៧៩៩៣ | |
| ៦ | អែម ចន្ទ្រា | ប្រុស | ០១៦ ៩០៩០៨៣ | |
| ៧ | ម៉ន ដាលីស | ស្រី | ០៩៥ ៩៤៤៩២៩ | |
| ៨ | ឡឿន វុទ្ធី | ប្រុស | ០៨១ ៧១៤១៥៣ | |
| ៩ | ស្វាយ សុផល្លា | ស្រី | ០១៧ ៣៨០២៨០ | |
| ១០ | ខេង វណ្ណារ៉ា | ប្រុស | ០៦៩ ២១៥៨៦៣ | |
| ១១ | យឹម រ៉ុន | ប្រុស | ០១០ ៧៤១០១៧ | |
| ១២ | ដែ កែវ | ប្រុស | ០៩៥ ៨៩២០០៥ | |
| ១៣ | រស់ សំអឿន | ប្រុស | ០៦៩ ៤៧៦៧៧៩៧ | |
| ១៤ | សិត ភាស់ | ប្រុស | ០៩៦ ៤៥៦២៣៩៧ | |
| ១៥ | ប៉ាង ស៊ីណា | ប្រុស | ០១៦ ២៣៦២៣១ | |
| ១៦ | សេង ម៉ានី | ប្រុស | ០៨១ ៩៧២៧២៧ | |


អរគុណ សន្តិភាព !
សេនាបតីតេជោ ហ៊ុន សែន ដែលបានកសាងសន្តិភាព




ទីចាត់ការ






ទីចាត់ការ